ព្រះរាជាណាចក្រកម្ពុជា

ជាតិ | សាសនា | ព្រះមហាក្សត្រ

# ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា ២០៣០




២០២១

ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ
បច្ចេកវិទ្យា និងនវានុវត្តន៍

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

# ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍កម្ពុជា ២០៣០

**ឆ្នាំ២០២១**

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

# អារម្ភកថា

ការពង្រឹងសមត្ថភាពខាងផ្នែកបច្ចេកវិទ្យា និងការលើកកម្ពស់សមិទ្ធកម្មនវានុវត្តន៍ គឺជាកត្តាគន្លឹះកំណត់ការសម្រេចឱ្យបាននូវទស្សនៈវិស័យប្រកបដោយមហិច្ឆតារបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) នឹងដើរតួនាទីជាចលករដែលមិនអាចខ្វះបានក្នុងការផ្លាស់ប្តូរបែបផែននៃការអភិវឌ្ឍសេដ្ឋកិច្ចចេញពីការផ្តោតលើកំណើនបែបប្រពៃណី ទៅជាកំណើនប្រកបដោយបរិយាប័ន្ន និងចីរភាព។ វិស័យ **វ.ប.ន.** នឹងជួយបង្កបរិយាកាស និងពន្លឿនបរិវត្តកម្មរចនាសម្ព័ន្ធ ដែលជាតម្រូវការចាំបាច់ក្នុងការលើកកម្ពស់វិបុលភាព សន្តិសុខ សុវត្ថិភាព ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងគុណភាពជីវិតឱ្យកាន់តែប្រសើរឡើងសម្រាប់ជាតិមាតុភូមិ។

ការរាតត្បាតនៃជំងឺកូវីដ-១៩ បានបង្កឱ្យមានវិបត្តិសុខភាពសាធារណៈយ៉ាងធ្ងន់ធ្ងរ ហើយបានបង្ករាំងស្ទះដល់កំណើនសេដ្ឋកិច្ចសង្គមជាសកល។ ជាក់ស្តែង ប្រទេសកម្ពុជាដែលទទួលបាននូវអត្រាកំណើនសេដ្ឋកិច្ចគួរឱ្យកត់សម្គាល់នាទសវត្សរ៍ចុងក្រោយនេះ ក៏ត្រូវជួបប្រទះនូវកំណើនថយចុះនៅឆ្នាំ២០២០ ដោយសារតែមានការរំខាននៃខ្សែច្រវ៉ាក់ផ្គត់ផ្គង់ក្នុងស្រុក និងសកល។ ស្ថិតក្នុងកាលៈទេសៈនេះ **ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០** គឺជាសម្បត្តិដ៏មានសារៈសំខាន់ និងទាន់សភាពការណ៍ក្នុងការតម្រង់ទិសមិនត្រឹមតែទៅរកការស្តារសេដ្ឋកិច្ចឡើងវិញប៉ុណ្ណោះទេ ថែមទាំងការធ្វើបរិវត្តកម្មរចនាសម្ព័ន្ធ ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនផលិតភាពទៀតផង។ ក្នុងន័យនេះ ផែនទីបង្ហាញផ្លូវនឹងជាកាតាលីករក្នុងការធ្វើបរិវត្តកម្មសេដ្ឋកិច្ច ពីសេដ្ឋកិច្ចអតិពលកម្ម ទៅជាសេដ្ឋកិច្ចផ្អែកលើជំនាញ ហើយប្រែក្លាយជាប្រជាជាតិមួយដែលយកនវានុវត្តន៍ ជាមូលដ្ឋានក្នុងការអភិវឌ្ឍ។

**ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០** នេះ ផ្តោតលើសសរស្តម្ភសំខាន់ចំនួន ៥ រួមមាន ១)អភិបាលកិច្ច ២)ការអប់រំ ៣)ការស្រាវជ្រាវនិងអភិវឌ្ឍន៍ ៤)កិច្ចសហការនិងបណ្តាញ និង៥)ប្រព័ន្ធអេកូឡូស៊ីសមប្រកប។ សសរស្តម្ភទាំងនេះ គឺស្របទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិផ្សេងៗ រួមមាន៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ២០១៩-២០២៣ គោលនយោបាយជាតិស្តីពី វ.ប.ន. ឆ្នាំ២០២០-២០៣០ ផែនការអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥ ជាដើម។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា **ផែនទីបង្ហាញផ្លូវ វ.ប.ន.** នេះ នឹងជាយាន្តសម្រាប់ការបោះជំហានក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រជាតិទាំងនេះបានយ៉ាងជោគជ័យ។

ដោយពិនិត្យឃើញថា វិស័យ វ.ប.ន. មានលក្ខណៈអន្តរវិស័យ និងប្រទាក់ក្រឡាគ្នា ខ្ញុំសូមអំពាវនាវ និងលើកទឹកចិត្តដល់តួអង្គពាក់ព័ន្ធ មានជាអាទិ៍៖ ក្រសួង-ស្ថាប័ន សាកលវិទ្យាល័យ មជ្ឈមណ្ឌលស្រាវជ្រាវ វិស័យឯកជន និងសង្គមស៊ីវិល ឱ្យសហការគ្នាអនុវត្តផែនទីបង្ហាញផ្លូវនេះ ដោយមានការសម្របសម្រួលពីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងចង្អុលបង្ហាញពីក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ក្រោមការរួបរួមសាមគ្គីគ្នា យើងប្រាកដជាអាចសម្រេចបាននូវឆន្ទៈដ៏ឧត្តុង្គឧត្តម ហើយឈានទៅសម្រេចបានចក្ខុវិស័យឆ្នាំ២០៥០។



ខ្ញុំសូមសម្តែងការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍** ដែលបានដឹកនាំ អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការរៀបចំ និងកសាងនូវឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់នេះឡើង។ ខ្ញុំក៏សូមថ្លែងអំណរគុណជូនចំពោះគណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ (UNESCAP) ដែលបានផ្តល់ការគាំទ្រផ្នែកបច្ចេកទេស និងការប្រឹក្សាយោបល់នៅក្នុងដំណើរការកសាងផែនទីបង្ហាញផ្លូវនេះ។

ថ្ងៃ ចន្ទ ៤ រោច ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# បុព្វកថា

**វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.)** គឺជាកម្លាំងចលករដ៏រឹងមាំដែលបាននិងកំពុងជំរុញឱ្យមានការអភិវឌ្ឍសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសអភិវឌ្ឍន៍ជឿនលឿនលើសកលលោក។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានយល់ជ្រួតជ្រាបយ៉ាងច្បាស់ថាវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់បង្កលក្ខណៈឱ្យប្រទេសកម្ពុជាឈានទៅសម្រេចបាននូវចក្ខុវិស័យប្រកបដោយមហិច្ឆតារបស់ខ្លួន ក្នុងការប្រែក្លាយទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ដើម្បីគាំទ្រដល់បេសកកម្មមួយនេះ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួង ឧ.វ.ប.ន.) ដែលពីមុនជាក្រសួងឧស្សាហកម្ម និងសិប្បកម្ម ត្រូវបានរាជរដ្ឋាភិបាលសម្រេចប្រគល់ភារកិច្ចថ្មីឱ្យដឹកនាំ និងគ្រប់គ្រងការអនុវត្តគោលនយោបាយជាតិស្តីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ឆ្នាំ២០២០-២០៣០ អមជាមួយនឹងភារកិច្ចដែលកំពុងអនុវត្ត ក្នុងនោះរួមមាន ការផ្តល់កិច្ចគាំទ្រដល់វិស័យឧស្សាហកម្ម សិប្បកម្ម និងទឹកស្អាត។ ជាមួយគ្នានេះ យោងតាមអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០២០ រាជរដ្ឋាភិបាលក៏បានប្រគល់ភារកិច្ចជូនក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងការសម្របសម្រួល និងអនុវត្តគំនិតផ្តួចផ្តើមទាំងឡាយ សំដៅពង្រឹងការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ ការអភិវឌ្ឍបច្ចេកវិទ្យា និងសមត្ថភាពនវានុវត្តន៍ក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មជំនាន់ទី៤។ បន្ថែមទៀតនោះ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក.ជ.វ.ប.ន.) ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ២០២០ និងមាន **សម្តេចតេជោនាយករដ្ឋមន្ត្រី** ជាប្រធានកិត្តិយស នឹងជួយតម្រង់ទិសក្នុងការលើកកម្ពស់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់គោលដៅអភិវឌ្ឍន៍ជាតិ។

ផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល និងដើម្បីឱ្យការបំពេញភារកិច្ចសម្រេចបានលទ្ធផលជោគជ័យ និងផ្លែផ្កាជាវិជ្ជមានតាមការគ្រោងទុក ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ បានរៀបចំ និងកសាងនូវ**ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០** ដែលជាឯកសារយុទ្ធសាស្ត្រដ៏មានសារៈសំខាន់និងចាំបាច់ ក្នុងគោលបំណងជួយតម្រង់ទិសក្នុងការអនុវត្តផែនការសកម្មភាពនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាភាគីពាក់ព័ន្ធទាំងឡាយ សម្រាប់ឈានទៅសម្រេចបាននូវចក្ខុវិស័យឆ្នាំ២០៥០ របស់រាជរដ្ឋាភិបាល។

**ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០** នេះ ត្រូវបានរៀបចំឡើងដោយមានការគាំទ្រយ៉ាងសកម្មពីសំណាក់ **គណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៃអង្គការសហប្រជាជាតិ (UNESCAP)** ក៏ដូចជាការចូលរួមចំណែកយ៉ាងធំធេងរបស់ក្រុមការងារប្រចាំនៅក្រសួងឧស្សាហកម្មវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ផែនទីបង្ហាញផ្លូវនេះ បានច្របាច់បញ្ចូលខ្លឹមសារអនុសាសន៍នៃគោលនយោបាយដោយផ្អែកលើទស្សីករណ៍ ក៏ដូចជាធាតុចូលសំខាន់ៗដែលបានមកពីភាគីពាក់ព័ន្ធជាច្រើន រួមមាន ថ្នាក់អគ្គនាយកនៃអគ្គនាយកដ្ឋាននៅតាមបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធចំនួន១៨ សាកលវិទ្យាធិការ និងប្រធានវិទ្យាស្ថានស្រាវជ្រាវមកពីស្ថាប័នឈានមុខចំនួន៨ នាយកប្រតិបត្តិមកពីក្រុមហ៊ុនជោគជ័យក្នុងវិស័យផ្សេងៗគ្នាចំនួន៨ និងថ្នាក់ដឹកនាំមជ្ឈមណ្ឌលពន្លឿនការបណ្តុះធុរកិច្ចចំនួន៣ ព្រមទាំងដៃគូអភិវឌ្ឍន៍អន្តរជាតិចំនួន៣ ផងដែរ។

**ផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០** ត្រូវបានតាក់តែងឡើងដោយមានសសរស្តម្ភចំនួន៥ ហើយក្នុងសសរស្តម្ភនីមួយៗ មានរៀបរាប់អំពីគោលដៅដ៏ជាក់លាក់ដែលត្រូវសម្រេចឱ្យបាននៅត្រឹមឆ្នាំ២០៣០។ **សសរស្តម្ភទី១** មានគោលដៅពង្រឹងអភិបាលកិច្ចនៃប្រព័ន្ធវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងគូសបញ្ជាក់ពីតួនាទីរបស់ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ក្នុងនាមជាស្ថាប័នដឹកនាំការសម្របសម្រួលលើការអនុវត្តគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ **សសរស្តម្ភទី២** មានគោលដៅកសាងធនធានមនុស្សក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ តាមរយៈការបង្កើនចំនួននិស្សិតដែលសិក្សាផ្នែកស្ទែម (STEM) នៅតាមសាកលវិទ្យាល័យ ឱ្យបានយ៉ាងតិចចំនួន ៥០%។ **សសរស្តម្ភទី៣** មានគោលដៅលើកកម្ពស់ការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ តាមរយៈការវិនិយោគចំនួន ១% នៃផលិតផលក្នុងស្រុកសរុបទៅលើសកម្មភាពស្រាវជ្រាវ។ **សសរស្តម្ភទី៤** មានគោលដៅពង្រឹងកិច្ចសហការ និងកសាងបណ្តាញទំនាក់ទំនងក្នុងចំណោមតួអង្គពាក់ព័ន្ធទាំងឡាយ។ ចុងក្រោយ **សសរស្តម្ភទី៥** មានគោលដៅជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់នវានុវត្តន៍ ការលើកកម្ពស់សមត្ថភាពស្រូបទាញក្រុមហ៊ុន ការទាក់ទាញការវិនិយោគនៅក្នុងវិស័យឧស្សាហកម្មទាក់ទិននឹងវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងការលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា។

ខ្ញុំសូមសម្តែងការកោតសរសើរខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់តួអង្គពាក់ព័ន្ធទាំងឡាយ ដែលបានចូលរួមនៅក្នុងដំណើរការកសាងផែនទីបង្ហាញផ្លូវនេះ។ វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាឆ្អឹងខ្នងដែលនាំឱ្យមានជោគជ័យនៅក្នុងដំណើរការអភិវឌ្ឍប្រទេស។ ពិតណាស់ នៅលើពិភពលោកយើងនេះ គ្មានប្រទេសណាមួយអាចគេចផុតពីអន្ទាក់នៃប្រទេសមានចំណូលមធ្យម និងប្រែក្លាយខ្លួនទៅជាប្រទេសរីកចម្រើនជឿនលឿន ដោយពុំមានយុទ្ធសាស្ត្រច្បាស់លាស់សម្រាប់ការអភិវឌ្ឍវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍បានឡើយ។ ក្រោមការដឹកនាំប្រកបដោយចក្ខុវិស័យដ៏ទូលំទូលាយ យូរអង្វែង និងគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** ការចាប់យកវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ គឺជាការសម្រេចចិត្តដ៏សំខាន់មួយ ដែលនឹងអនុញ្ញាតឱ្យប្រទេសកម្ពុជាឈានជើងចូលទៅក្នុងសករាជថ្មីនៃអារ្យធម៌ដ៏រស់រវើក។

ក្នុងនាមជាទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ខ្ញុំមានការប្តេជ្ញាចិត្តខ្ពស់ក្នុងការលើកកម្ពស់វិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដើម្បីឈានទៅសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្នសម្រាប់ជាតិមាតុភូមិកម្ពុជា។

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែទុតិយាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ២០២១

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**
**និងជាប្រធានក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា**
**និងនវានុវត្តន៍**

***កិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ***

# សេចក្តីថ្លែងអំណរគុណ

ផែនទីបង្ហាញផ្លូវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ នេះត្រូវបានរៀបចំតាក់តែងឡើង នៅឆ្នាំ២០២១ ដើម្បីផ្តល់ទិសដៅក្នុងការអនុវត្តគោលនយោបាយជាតិ វ.ប.ន.។ ផែនទីបង្ហាញផ្លូវនេះ ត្រូវបាន រៀបចំឡើងដោយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួង ឧ.វ.ប.ន.) ក្រោមការ ត្រួតពិនិត្យពី ឯកឧត្តមបណ្ឌិត ហ៊ុល សៀងហេង ជាអគ្គនាយកនៃអគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ (អ.វ.ប.ន.) នៃក្រសួង ឧ.វ.ប.ន. ជាមួយនឹងការគាំទ្ររបស់ផ្នែកពាណិជ្ជកម្ម វិនិយោគ និងនវានុវត្តន៍ នៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនៃអង្គការសហប្រជាជាតិ (UNESCAP)។

គ្រោងដើមនៃផែនទីបង្ហាញផ្លូវនេះត្រូវបានព្រាងដោយលោកស្រី Francie Sadeski និងលោក Matthieu Lacave ជាអ្នកប្រឹក្សាយោបល់ និងអ្នកគ្រប់គ្រងទូទៅនៃ Technopolis Group ជាមួយការគាំទ្រពី លោក Rafael Torquato Cruz ជាមន្ត្រីគម្រោងបច្ចេកវិទ្យានិងនវានុវត្តន៍របស់ ESCAP និងត្រួតពិនិត្យដោយ លោកស្រី Marta Pérez Cusó មន្ត្រីផ្នែកកិច្ចការសេដ្ឋកិច្ចរបស់ ESCAP ។

ផែនទីបង្ហាញផ្លូវនេះត្រូវបានបញ្ចូលធាតុចូលសំខាន់ៗប្រមូលបានពីតួអង្គពាក់ព័ន្ធទាំងឡាយនៅក្នុង ដំណើរការនៃការបង្កើតផែនទីបង្ហាញផ្លូវ ដែលជាដំណើរការគាំទ្រដោយ ក្រសួង ឧ.វ.ប.ន. និងគ្រប់គ្រងការរៀបចំ យ៉ាងហ្មត់ចត់ដោយ លោកបណ្ឌិត ស្រ៊ុន បញ្ញារិទ្ធិ ប្រធាននាយកដ្ឋានគោលនយោបាយវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (វ.ប.ន.) ដោយមានការគាំទ្រពី៖

- លោកបណ្ឌិត ទ្រី សុផល អគ្គនាយករងនៃ អ.វ.ប.ន.
- លោកស្រីបណ្ឌិត គ្រី ណាល់លីស អគ្គនាយិការងនៃ អ.វ.ប.ន.
- លោក អ៊ិន សំបូរ អគ្គនាយករងនៃ អ.វ.ប.ន.
- លោក កែ ប៊ុនធឿន ប្រធាននាយកដ្ឋានផ្ទេរបច្ចេកវិទ្យា
- លោកស្រី សេង មូលិកា ប្រធាននាយកដ្ឋានគ្រប់គ្រងព័ត៌មាន វ.ប.ន.
- លោកស្រីបណ្ឌិត លី សុខនី ប្រធាននាយកដ្ឋានសហប្រតិបត្តិការវិស័យ វ.ប.ន. និង
- លោកបណ្ឌិត ជាតិ សុផល ប្រធាននាយកដ្ឋានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្ត គោលនយោបាយ។

ដំណើរការកសាងផែនទីបង្ហាញផ្លូវត្រូវបានចូលរួមសម្របសម្រួលដោយ លោក Kal Joffres នាយក ប្រតិបត្តិនៃក្រុមហ៊ុន Tandemic។

សូមថ្លែងអំណរគុណដល់ការចូលរួមយ៉ាងយកចិត្តទុកដាក់ ពីសំណាក់តំណាងតួអង្គពាក់ព័ន្ធជាតិជាច្រើន ដែលបានរួមចំណែកក្នុងការផ្តល់បទសម្ភាសន៍ និងបានចូលរួមសិក្ខាសាលាផ្លាស់ប្តូរយោបល់ ដើម្បីផ្តល់ធាតុចូល សំខាន់ៗក្នុងការរៀបចំកសាងផែនទីបង្ហាញផ្លូវនេះឡើង។

# បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ

| | |
|---|---|
| EDF | មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព |
| ESCAP | គណៈកម្មការសេដ្ឋកិច្ចនិងសង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក |
| FDI | ការវិនិយោគផ្ទាល់ពីបរទេស |
| GDP (ផ.ស.ស.) | ផលិតផលក្នុងស្រុកសរុប |
| ICT | បច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ |
| MISTI | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| MOEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MOH | ក្រសួងសុខាភិបាល |
| MPTC | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ |
| NCSTI | ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| R&D | ការស្រាវជ្រាវ និងអភិវឌ្ឍន៍ |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស |
| SME | សហគ្រាសធុនតូច និងមធ្យម |
| STEM (ស្ទែម) | វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា |
| STI | វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ |
| TVET (ធីវេត) | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ |
| UNESCO | អង្គការសិក្សាវិទ្យាសាស្ត្រ អប់រំ និងវប្បធម៌នៃអង្គការសហប្រជាជាតិ |

# មាតិកា


អារម្ភកថា ....................................................................................................I-II

បុព្វកថា ........................................................................................................ i-ii

សេចក្តីថ្លែងអំណរគុណ ........................................................................................ iii

បញ្ជីអក្សរកាត់ និងពាក្យគន្លឹះ ............................................................................... iv

១. សេចក្តីផ្តើម .......................................................................................................១

២. ទិដ្ឋភាពទូទៅនៃផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ ............៣

៣. សសរស្តម្ភទាំង ៥ នៃផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០ .....៧

៣.១ ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ជាតិ ..............................................៧

*៣.១.១ គោលដៅគោលនយោបាយ ...........................................................៧*

*៣.១.២ ការពិពណ៌នាអំពីសកម្មភាព និងលិខិតូបករណ៍ .........................................៧*

*៣.១.៣ គោលនយោបាយចម្រុះ ..................................................................១១*

៣.២ ការកសាងធនធានមនុស្សផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ .................. ១៣

*៣.២.១ គោលដៅគោលនយោបាយ ...........................................................១៣*

*៣.២.២ ការពិពណ៌នាអំពីសកម្មភាព និងលិខិតូបករណ៍.........................................១៤*

*៣.២.៣ គោលនយោបាយចម្រុះ ..................................................................១៨*

៣.៣ ការពង្រឹងសមត្ថភាពស្រាវជ្រាវនិងគុណភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានស្រាវជ្រាវ សាធារណៈ និងសាកលវិទ្យាល័យ ..........................................................២០

*៣.៣.១ គោលដៅគោលនយោបាយ ........................................................... ២០*

*៣.៣.២ ការពិពណ៌នាអំពីសកម្មភាព និងលិខិតូបករណ៍....................................... ២០*

*៣.៣.៣ គោលនយោបាយចម្រុះ ..................................................................២៤*

៣.៤ ការបង្កើនការសហការនិងបណ្តាញក្នុងចំណោមអ្នកពាក់ព័ន្ធនៅក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ..... ២៦

*៣.៤.១ គោលដៅគោលនយោបាយ ........................................................... ២៦*

*៣.៤.២ ការពិព៌ណនាអំពីសកម្មភាព និងលិខិតូបករណ៍....................................... ២៦*

*៣.៤.៣ គោលនយោបាយចម្រុះ .................................................................. ៣០*

៣.៥ ការជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការកសាងសមត្ថភាពស្រូបយក នៅក្នុងក្រុមហ៊ុន និងទាក់ទាញការវិនិយោគនៅក្នុងវិស័យ វ.ប.ន........................ ៣២

*៣.៥.១ គោលដៅគោលនយោបាយ ........................................................... ៣២*

*៣.៥.២ ការពិពណ៌នាអំពីសកម្មភាព និងលិខិតូបករណ៍....................................... ៣២*

*៣.៥.៣ គោលនយោបាយចម្រុះ .................................................................. ៣៥*

**ឧបសម្ព័ន្ធ** ........................................................................................... ៣៧

# តារាង

តារាងទី ១៖ ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ជាតិ ....................................................៧
តារាងទី ២៖ គោលនយោបាយចម្រុះ៖ អភិបាលកិច្ច ..........................................................១១
តារាងទី ៣៖ កសាងធនធានមនុស្សក្នុងវិស័យ វ.ប.ន. .......................................................១៤
តារាងទី ៤៖ គោលនយោបាយចម្រុះ៖ ការអប់រំ ...............................................................១៨
តារាងទី ៥៖ ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាពស្រាវជ្រាវ .......................................២១
តារាងទី ៦៖ គោលនយោបាយចម្រុះ៖ ការស្រាវជ្រាវ ..........................................................២៤
តារាងទី ៧៖ បង្កើនកិច្ចសហការ និងបណ្តាញទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធក្នុង វិស័យ វ.ប.ន. .....២៧
តារាងទី ៨៖ គោលនយោបាយចម្រុះ៖ កិច្ចសហការ និងបណ្តាញ .........................................៣០
តារាងទី ៩៖ ការជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការកសាងសមត្ថភាពស្រូបយក
នៅក្នុងក្រុមហ៊ុន និងទាក់ទាញការវិនិយោគនៅក្នុងវិស័យ វ.ប.ន. .........................៣៣
តារាងទី ១០៖ គោលនយោបាយចម្រុះ៖ ប្រព័ន្ធអេកូឡូស៊ីដែលបរិយាកាសល្អ ..........................៣៥

# ១. សេចក្តីផ្តើម

នវានុវត្តន៍គឺជាដំណោះស្រាយប្រកបដោយប្រសិទ្ធភាពមួយដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមបន្ទាន់ៗនៅក្នុងការអភិវឌ្ឍ ដូចជា ការទទួលបានការផ្គត់ផ្គង់ទឹក ការលុបបំបាត់ជំងឺដែលមិនគួរកើត ឬការកាត់បន្ថយភាពអត់ឃ្លាន។ ការផ្ទេរបច្ចេកវិទ្យា និងការចាប់យកបច្ចេកវិទ្យាពីប្រទេសអភិវឌ្ឍន៍ អាចជាមធ្យោបាយមួយរួមចំណែកជួយឱ្យសម្រេចបាននូវគោលដៅទាំងនេះ។ កិច្ចខិតខំប្រឹងប្រែងច្បាស់លាស់មួយតាមរយៈការសិក្សាស្រាវជ្រាវគឺជាកិច្ចការចាំបាច់ដែលត្រូវធ្វើដើម្បីស្វែងរកដំណោះស្រាយនានា សំដៅឆ្លើយតបនឹងបញ្ហាប្រឈមជាសកលផ្សេងទៀត។ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដែលមានការចូលរួមរវាងស្ថាប័នសាធារណៈ និងឯកជន គឺជាយន្តការដ៏សំខាន់មួយក្នុងការស្វែងរកដំណោះស្រាយដែលជាតម្រូវការបំផុត។

ជាងនេះទៅទៀត មេរៀនដ៏សំខាន់មួយក្នុងអំឡុងពីរទសវត្សរ៍ចុងក្រោយនេះបានសឱ្យឃើញជាក់ច្បាស់ពីតួនាទីស្នូលរបស់នវានុវត្តន៍ក្នុងការធ្វើឱ្យសេដ្ឋកិច្ចរីកលូតលាស់។ ការកសាងសមត្ថភាពនវានុវត្តន៍ដើរតួនាទីជាមូលដ្ឋានសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជោគជ័យ។ ប្រទេសទាំងនេះបានទទួលស្គាល់ថា នវានុវត្តន៍មិនមែនផ្តោតតែលើផលិតផលដែលមានបច្ចេកវិទ្យាខ្ពស់នោះទេ ប៉ុន្តែក៏ចាំបាច់ត្រូវកសាងសមត្ថភាពនវានុវត្តន៍ក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍដែរ ព្រោះថាការរៀនសូត្រអាចជំរុញឱ្យប្រទេសដើរទាន់សម័យកាល។ គេក៏ត្រូវការសមត្ថភាពខាងនវានុវត្តន៍ផងដែរ ដើម្បីដោះស្រាយបញ្ហាប្រឈមនានានៅក្នុងស្រុក ដូចជា ជំងឺរាតត្បាតផ្សេងៗជាដើម។ ជាចុងក្រោយ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែលជោគជ័យត្រូវតែមានបញ្ចូលសកម្មភាពកសាងសមត្ថភាពនវានុវត្តន៍ដ៏ទូលំទូលាយមួយដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច។

ដោយមើលឃើញបញ្ហាប្រឈមខាងមុខ **សម្តេចតេជោនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានអនុម័តគោលនយោបាយជាតិ វ.ប.ន. ឆ្នាំ២០២០-២០៣០ នៅខែធ្នូ ឆ្នាំ២០១៩។ គោលដៅចម្បងនៃគោលនយោបាយជាតិ វ.ប.ន. គឺ ពង្រឹងមូលដ្ឋានគ្រឹះ វ.ប.ន. «ជាអាទិ៍៖ ធនធានមនុស្សក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) និងពង្រឹងស្ថាប័ន» និងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអេកូឡូស៊ី វ.ប.ន. ដើម្បីគាំទ្រឱ្យមានបរិស្ថានពោរពេញដោយនវានុវត្តន៍សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន «ជាអាទិ៍៖ លក្ខខណ្ឌនៃក្របខ័ណ្ឌផ្សេងៗ បទប្បញ្ញត្តិ និងច្បាប់ពាក់ព័ន្ធ និងភាពប្រទាក់ក្រឡាក្នុងចំណោមស្ថាប័នពាក់ព័ន្ធទាំងឡាយ»។

ដើម្បីសម្រេចគោលដៅទាំងឡាយដែលមានចែងនៅក្នុងគោលនយោបាយជាតិ វ.ប.ន. រាជរដ្ឋាភិបាលបានស្វែងរកកិច្ចសហការដើម្បីបង្កើតផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ សំដៅគាំទ្រក្រសួង និងស្ថាប័នពាក់ព័ន្ធនានាលើសកម្មភាពដែលត្រូវធ្វើក្នុងរយៈពេលខ្លី និងមធ្យមរហូតដល់ឆ្នាំ២០៣០។ ផែនទីបង្ហាញផ្លូវឆ្នាំ២០៣០ ដែលជាឯកសារបង្ហាញពីការអនុវត្តគោលនយោបាយជាតិ វ.ប.ន. បានកំណត់គោលដៅច្បាស់លាស់ តាមរយៈការដាក់ចេញនូវសំណុំសកម្មភាពសំខាន់ៗដោយមានពេលវេលាកំណត់ និងចំណុចដៅជាក់លាក់ ដើម្បីសម្រេចឱ្យបាននៅឆ្នាំ២០៣០។ ឯកសារនេះបង្ហាញតួនាទីច្បាស់លាស់របស់ក្រសួង ឧ.វ.ប.ន. ដើម្បីពិនិត្យពិច័យ និងសម្របសម្រួលរាល់ការអនុវត្តគោលនយោបាយជាតិស្តីពី វ.ប.ន នៅតាមបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ។

រាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំឱ្យមានការគាំទ្រពី UNESCAP ដើម្បីរៀបចំកសាងផែនទីបង្ហាញផ្លូវក្នុងគោលដៅអនុវត្តគោលនយោបាយជាតិស្តីពី វ.ប.ន.។ កន្លងមក UNESCAP ធ្លាប់បានផ្តល់នូវការណែនាំជាគោលនយោបាយមួយចំនួនក្នុងដំណាក់កាលដំបូងៗ នៅពេលកំពុងកសាងគោលនយោបាយជាតិស្តីពី វ.ប.ន. សំដៅជួយឱ្យប្រទេសកម្ពុជាសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន។ UNESCAP ក៏បានសហការជាមួយក្រុមហ៊ុនប្រឹក្សាយោបល់ Technopolis Group ដើម្បីគាំទ្រដល់ការកសាងផែនទីបង្ហាញផ្លូវនេះ។

ផែនទីបង្ហាញផ្លូវត្រូវបានកសាងឡើងផ្អែកទៅលើការវាយតម្លៃនៃប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជា (Cambodia's National Innovation System) ដែលចេញផ្សាយជាច់ដោយឡែកក្រោមចំណងជើងថា «ប្រព័ន្ធអេកូឡូស៊ី វ.ប.ន. កម្ពុជា» និងការប្រឹក្សាយោបល់ធ្វើឡើងជាមួយដៃគូទាំងឡាយក្នុងបណ្តាក្រសួង ស្ថាប័នអប់រំ និងវិស័យឯកជន តាមរយៈបទសម្ភាសន៍ និងសិក្ខាសាលាផ្លាស់ប្តូរយោបល់។ បញ្ជីឈ្មោះដៃគូមានភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ។ យោងតាមសេចក្តីណែនាំក្នុងផែនទីបង្ហាញផ្លូវនេះ ការអនុវត្តលិខិតូបករណ៍គោលនយោបាយនឹងកាន់តែប្រសើរឡើង តាមរយៈការពិគ្រោះប្រឹក្សាយោបល់បន្ថែមទៀតជាមួយស្ថាប័នហិរញ្ញវត្ថុជាតិ និងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍ផ្សេងៗ រួមមាន អង្គការយូណេស្កូ ធនាគារបច្ចេកវិទ្យារបស់អង្គការសហប្រជាជាតិ អង្គការអភិវឌ្ឍន៍ឧស្សាហកម្មរបស់អង្គការសហប្រជាជាតិ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិចិន ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ។ល។

ក្នុងរបាយការណ៍នេះ ការស្រាវជ្រាវ និងអភិវឌ្ឍន៍ ត្រូវបានកំណត់និយមន័យថាជាវិធីនៃការបង្កើតចំណេះដឹងថ្មី ព្រមទាំងមានការឯកភាពគ្នាទៅលើនិយមន័យនៃពាក្យនវានុវត្តន៍ ដែលកំណត់ដោយអង្គការសម្រាប់កិច្ចសហប្រតិបត្តិការនិងអភិវឌ្ឍន៍សេដ្ឋកិច្ច (Organization for Economic Co-operation and Development - OECD) ដែលមានចែងក្នុងសៀវភៅណែនាំអូស្លូ (Oslo Manual)។ នវានុវត្តន៍មិនមានអត្ថន័យត្រឹមតែជាការស្រាវជ្រាវក្នុងបរិវេណមន្ទីរពិសោធន៍ប៉ុណ្ណោះទេ ប៉ុន្តែវាមានវិសាលភាពគ្របដណ្តប់ទាំងអ្នកប្រើប្រាស់ អ្នកផ្គត់ផ្គង់ និងអតិថិជន នៅគ្រប់មជ្ឈដ្ឋានដូចជានៅក្នុងរដ្ឋាភិបាល ធុរកិច្ច និងអង្គការមិនស្វែងរកប្រាក់ចំណេញ ព្រមទាំងមានលក្ខណៈអន្តរវិស័យ និងស្ថាប័ន។ យោងតាមសៀវភៅណែនាំអូស្លូ នវានុវត្តន៍មាន ៤ ប្រភេទរួមមាន៖

- នវានុវត្តន៍ផលិតផល (Product Innovation)៖ ផលិតផលមួយ ឬសេវាកម្មមួយដែលថ្មី និងប្រសើរជាងមុន រួមមាន ការច្នៃប្រឌិតសំខាន់ៗ ដោយផ្តោតលើលក្ខណៈពិសេសនៃបច្ចេកទេស គ្រឿងបង្គុំ និងរូបធាតុ សូហ្វវែរ(Software)ក្នុងផលិតផល ភាពងាយស្រួលប្រើ ឬលក្ខណៈមុខងារផ្សេងៗទៀត។
- នវានុវត្តន៍ដំណើការ (Process Innovation)៖ ផលិតកម្ម ឬវិធីសាស្ត្រចែកចាយ ដែលថ្មី ឬប្រសើរជាងមុន រួមមាន ភាពប្រែប្រួលគួរឱ្យកត់សម្គាល់លើទិដ្ឋភាពបច្ចេកទេស សម្ភារ និង/ឬ ប្រព័ន្ធកម្មវិធី។
- នវានុវត្តន៍ទីផ្សារ (Marketing Innovation)៖ វិធីសាស្ត្រទីផ្សារថ្មីមួយដែលមានលក្ខណៈប្រែប្រួលគួរឱ្យកត់សម្គាល់ តាមរយៈការរចនាផលិតផល ឬសំបកវេចខ្ចប់ ការជំនួសដោយផលិតផលថ្មី ការផ្សព្វផ្សាយផលិតផល ឬការកំណត់តម្លៃ។
- នវានុវត្តន៍រចនាសម្ព័ន្ធ (Organizational Innovation)៖ វិធីសាស្ត្ររៀបចំរចនាសម្ព័ន្ធថ្មីមួយក្នុងការធ្វើអាជីវកម្មជាក់ស្តែង រចនាសម្ព័ន្ធនៅកន្លែងការងារ ឬទំនាក់ទំនងខាងក្រៅ។

# ២. ទិដ្ឋភាពទូទៅនៃផែនទីបង្ហាញផ្លូវវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០

គោលនយោបាយជាតិស្តីពី វ.ប.ន. មានគោលដៅជំរុញវិស័យ វ.ប.ន. ឱ្យក្លាយជាកម្លាំងចលករដ៏សំខាន់ក្នុងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយចីរភាពនិងបរិយាប័ន្ន ដើម្បីឈានទៅសម្រេចចក្ខុវិស័យរបស់រាជរដ្ឋាភិបាល សំដៅធ្វើឱ្យកម្ពុជាក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០ និងឈានទៅសម្រេចគោលដៅជាតិសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព។ គោលដៅនៃគោលនយោបាយ វ.ប.ន. គឺការឈានទៅពង្រឹងមូលដ្ឋានគ្រឹះ វ.ប.ន. លើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាការកសាងលក្ខខណ្ឌដែលអំណោយផលដល់ការរីកលូតលាស់នៃវិស័យវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព និងឈានទៅលើកកម្ពស់គុណភាពនៃការរស់នៅរបស់ប្រជាជននៅគ្រប់កម្រិតនិងគ្រប់វិស័យ។ គោលដៅខាងលើនេះអាចនឹងសម្រេចទៅបាន លុះត្រាតែមានការសម្របខ្លួន ក៏ដូចជាការចាប់យកបច្ចេកវិទ្យាថ្មីៗ និងការបន្តលើកកម្ពស់វិស័យនវានុវត្តន៍បន្ថែមទៀត។

ការលើកកម្ពស់ វ.ប.ន. ក៏ត្រូវបានដាក់បញ្ចូលផងដែរនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ ក៏ដូចជានៅក្នុងចក្ខុវិស័យឆ្នាំ២០៥០ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៩-២០២៣ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៥-២០២៥។ ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់សុទ្ធតែបានដាក់បញ្ចូលគោលដៅជាក់លាក់សម្រាប់លើកស្ទួយវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា (ស្ទែម) និងនវានុវត្តន៍ ទៅក្នុងយុទ្ធសាស្ត្ររបស់ខ្លួន។ វិស័យអាទិភាពនៅក្នុងសេដ្ឋកិច្ចកម្ពុជាត្រូវបានផ្តោតលើវិស័យកសិកម្ម ឧស្សាហកម្ម «កម្មន្តសាល» និងសេវាកម្មឌីជីថលផ្សេងទៀត។

គោលនយោបាយជាតិស្តីពី វ.ប.ន. ផ្តោតសំខាន់លើដែនដែលមានលក្ខណៈវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាលើវិស័យអាទិភាពចំនួន ៥៖

- ការលើកកម្ពស់ទិន្នផលកសិកម្ម ពិពិធកម្មផលិតផល និងការកែច្នៃកសិផល
- ទំនើបកម្មផលិតកម្ម និងវិស្វកម្ម
- សុខាភិបាល និងជីវវេជ្ជសាស្ត្រ
- វិទ្យាសាស្ត្ររូបធាតុ (Material Science) និងវិស្វកម្ម
- សេវាកម្ម និងសេដ្ឋកិច្ចឌីជីថល រួមមាន បញ្ញាសិប្បនិម្មិត បច្ចេកវិទ្យាលំហ និងអវកាស។

ជាការពិតណាស់ ប្រព័ន្ធនវានុវត្តន៍កម្ពុជាកំពុងស្ថិតក្នុងដំណាក់កាលនៃការអភិវឌ្ឍនៅឡើយ។ ជាក់ស្តែងក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤។ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ (ក្រសួង ឧ.វ.ប.ន.) ត្រូវបានបង្កើតឡើងនៅខែមីនា ឆ្នាំ២០២០ ហើយអភិបាលកិច្ចវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវបានគិតគូររៀបចំឡើងវិញនៅឆ្នាំ២០២០។

ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ ត្រូវបានកសាងឡើងក្នុងគោលបំណងដើម្បីតម្រង់ទិសការអនុវត្តគោលនយោបាយជាតិ វ.ប.ន.។ ការកសាងផែនទីបង្ហាញផ្លូវនេះគឺផ្អែកទៅលើគោលការណ៍ពីរយ៉ាង រួមមាន

(១) ក្របខ័ណ្ឌគំនិតនៃប្រព័ន្ធនវានុវត្តន៍ជាតិ (National Innovation System) ដែលបង្ហាញថា នវានុវត្តន៍គឺជាលទ្ធផលដែលកើតចេញពីការចូលរួមសហការគ្នារវាងតួអង្គពាក់ព័ន្ធនានានៅក្នុងបរិបទជាក់លាក់ណាមួយ ហើយការលើក កម្ពស់វិស័យនវានុវត្តន៍គឺត្រូវអនុវត្តអភិក្រមដែលមានលក្ខណៈជាប្រព័ន្ធ[1] និង (២) ការគិតគូរពិចារណាពីចំណុចខ្លាំងនិងចំណុចខ្សោយនៃប្រព័ន្ធនវានុវត្តន៍ជាតិកម្ពុជានាពេលបច្ចុប្បន្ន[2]។ រូបភាពទី ១ នៅខាងក្រោម គឺជាតារាងសង្ខេបអំពីផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០។




**រូបភាពទី ១៖ សេចក្តីសង្ខេបផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០**

- **ពង្រឹងអភិបាលកិច្ចរបស់ប្រព័ន្ធ វ.ប.ន.៖** អភិបាលកិច្ច វ.ប.ន. គឺជាគន្លឹះដ៏មានសារៈសំខាន់ ហើយត្រូវបានរៀបចំរចនាសម្ព័ន្ធឡើងវិញតាមរយៈការបង្កើតក្រសួង ឧ.វ.ប.ន. នាខែមីនា ឆ្នាំ២០២០។ វាមានសារៈសំខាន់ណាស់ក្នុងការពង្រឹងរចនាសម្ព័ន្ធថ្មីនេះ ដោយកាត់បន្ថយការបែងចែកនិងការធ្វើការដាច់ដោយឡែកគ្នាពីរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ ប៉ុន្តែតម្រូវឱ្យមានការកំណត់តួនាទីរបស់ក្រសួង ឧ.វ.ប.ន. និងក្រសួងស្ថាប័នពាក់ព័ន្ធដទៃទៀត ព្រមទាំងពង្រឹងការយល់ដឹង និងសមត្ថភាពរបស់

[1] Freeman, C. (1987). Technology Policy and Economic Performance: Lessons from Japan. London: Pinter; Lundvall, B-Å ed. (1992). National Systems of Innovation: Towards a Theory of Innovation and Interactive Learning. London: Pinter; Nelson, R.R. (1993). National Innovation Systems: a Comparative Study. New York: Oxford University Press.

[2] សូមអានការវាយតម្លៃលម្អិតនៅក្នុង "របាយការណ៍វិភាគអំពីប្រព័ន្ធអេកូឡូស៊ីវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍"។

រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយស្ដីពី វ.ប.ន. ក៏ដូចជាការត្រួតពិនិត្យតាមដាន និងវាយតម្លៃសកម្មភាពលើកកម្ពស់វិស័យ វ.ប.ន.។

- **កសាងធនធានមូលធនក្នុងវិស័យ វ.ប.ន.៖** តម្រូវការនវានុវត្តន៍នៅមានកម្រិតទាបនៅឡើយ ហើយវប្បធម៌នៃវិទ្យាសាស្ត្រ និងសហគ្រិនភាពថ្មី ក៏នៅមានកម្រិតដែរក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។ វាមានសារៈសំខាន់ណាស់ក្នុងការលើកកម្ពស់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រ ឌីជីថល និងសហគ្រិនភាព ក៏ដូចជាការត្រៀមខ្លួនជាស្រេចក្នុងការចាប់យកបច្ចេកវិទ្យាថ្មីក្នុងចំណោមយុវជន ដោយចាប់ផ្ដើមពីការអប់រំថ្នាក់មូលដ្ឋានឡើងទៅ។ ការបង្រៀនផ្នែក វ.ប.ន. ដល់កុមារនឹងជួយបង្កើតឱ្យមានអ្នកវិទ្យាសាស្ត្រ និងអ្នកនវានុវត្តន៍ជំនាន់ថ្មី។ ជំនាញផ្នែកស្ទែម ក៏ត្រូវការការលើកកម្ពស់នៅក្នុងថ្នាក់ឧត្តមសិក្សាផងដែរ។ លើសពីនេះទៀត ការបង្រៀន និងកិច្ចសហការជាមួយវិស័យឯកជននៅតាមស្ថាប័ន អប់រំ បណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ(ជីវេត) នៅមានកម្រិតនៅឡើយ និងគួរត្រូវបានគិតគូរពង្រឹងបន្ថែមទៀត។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ធនធានមនុស្សគឺជាមូលដ្ឋានគ្រឹះក្នុងការលើកកម្ពស់វិស័យ វ.ប.ន.។
- **ពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាព៖** កសាងសមត្ថភាពគ្រឹះស្ថានឧត្តមសិក្សា និងប្រព័ន្ធស្រាវជ្រាវ គឺជាកិច្ចការចាំបាច់មួយ ដើម្បីទទួលបាននូវការស្រាវជ្រាវនិងអភិវឌ្ឍន៍ ប្រកបដោយគុណភាពខ្ពស់ ស្របទៅតាមផលប្រយោជន៍ជាតិ និងនៅក្នុងវិស័យអាទិភាព។ ដើម្បីសម្រេចគោលដៅនេះ តម្រូវឱ្យមានការបង្កើតរបៀបវារៈស្រាវជ្រាវថ្នាក់ជាតិ (National Research Agenda) ជាមួយសហគមន៍អ្នកសិក្សាស្រាវជ្រាវ និងសហការយ៉ាងជិតស្និទ្ធជាមួយវិស័យឯកជន តាមរយៈការផ្ដល់ជាមូលនិធិដើម្បីគាំទ្រស្នាដៃលេចធ្លោពាក់ព័ន្ធនឹងវិទ្យាសាស្ត្រ ការធ្វើអន្តរជាតូបនីយកម្មកិច្ចការស្រាវជ្រាវ ព្រមទាំងការលើកទឹកចិត្តឱ្យមានកិច្ចសហការជាមួយវិស័យឯកជន។
- **បង្កើនកិច្ចសហការនិងបណ្ដាញរវាងតួអង្គពាក់ព័ន្ធ៖** នវានុវត្តន៍បានមកពីការផ្លាស់ប្ដូរគំនិតក្នុងចំណោមបុគ្គល អង្គការ វិស័យ និងផ្នែកវិទ្យាសាស្ត្រជាដើម។ អង្គភាពអន្តរការី (Intermediary Organization) និង អង្គភាពឈ្មួញកណ្ដាលចំណេះដឹង(Knowledge Broker Institution) គឺជាតួអង្គដ៏សំខាន់ក្នុងការដើរតួជាអ្នកសម្របសម្រួលឱ្យមានការផ្លាស់ប្ដូរគំនិតយោបល់គ្នា។ ដូច្នេះហើយ វាមានភាពចាំបាច់ណាស់ក្នុងការជំរុញ និងជានានិរន្តភាពបរិក្ខារឧបទេសភ្ញាស់និងពន្លឿន (Incubation and Acceleration Facilities) និងវេទិកាបច្ចេកវិទ្យា ដែលបើកចំហដល់វិស័យឯកជន និងបណ្ដុំស្ថាប័នដែលមានលក្ខណៈនវានុវត្តន៍ (Innovative Clusters) សំដៅជំរុញកិច្ចសហប្រតិបត្តិការ ដើម្បីគាំទ្រដល់នវានុវត្តន៍ នៅតាមបណ្ដាសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងលើកកម្ពស់សមត្ថភាពស្រូបយកបច្ចេកវិទ្យា និងចំណេះដឹងថ្មីរបស់សហគ្រាសទាំងនោះ។
- **ជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការពង្រឹងសមត្ថភាពស្រូបយកបច្ចេកវិទ្យា និងចំណេះដឹងថ្មីនៅក្នុងក្រុមហ៊ុន និងទាក់ទាញការវិនិយោគលើវិស័យ វ.ប.ន.៖** ការគាំទ្រដល់សមត្ថភាពនវានុវត្តន៍ និងបង្កើនសមត្ថភាពស្រូបយករបស់ក្រុមហ៊ុន ទាមទារឱ្យមានហិរញ្ញប្បទាន និងការលើកកម្ពស់របនាសម្ព័ន្ធអន្តរការីដែលជួយបណ្ដុះធុរកិច្ចថ្មី (Start-Up) ក៏ដូចជាគាំទ្រការផ្ទេរបច្ចេកវិទ្យា និងលើក

កម្ពស់បច្ចេកវិទ្យាក្នុងស្រុក។ លើសពីនេះទៅទៀត គេក៏ចាំបាច់ត្រូវជួយជំរុញស្ថាប័នណាដែលមានសមត្ថកិច្ចក្នុងការផ្តល់សេវាកម្មបច្ចេកវិទ្យា និងគុណភាព (ដូចជា បទដ្ឋាននិងវិញ្ញាបនបត្រកម្ម) ទៅដល់បណ្តាក្រុមហ៊ុន។ ម្យ៉ាងទៀត វាក៏ទាមទារនូវការបង្កើនលទ្ធភាពទទួលបានហិរញ្ញប្បទាន សម្រាប់សកម្មភាពនវានុវត្តន៍ តាមរយៈការលើកកម្ពស់ការវិនិយោគពីវិស័យឯកជន និងការទាក់ទាញប្រភពថវិកាពីម្ចាស់ជំនួយ។ ការលើកទឹកចិត្តឱ្យមានការវិនិយោគផ្ទាល់ពីបរទេស ដែលគាំទ្រដល់ការកសាងសមត្ថភាពបច្ចេកវិទ្យាក្នុងស្រុក ការសម្របសម្រួលការនាំចូលឧបករណ៍បច្ចេកទេស និងការលើកកម្ពស់កម្មសិទ្ធិបញ្ញា គឺជាមធ្យោបាយបន្ថែមក្នុងការជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការអនុវត្តនវានុវត្តន៍។

ការអនុវត្តវិស័យអាទិភាពទាំងនេះត្រូវពឹងផ្អែកលើ **ភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន។** ក្រុមហ៊ុនធុរកិច្ចថ្មី សហគ្រាសធុនតូច និងមធ្យម សាជីវកម្មបរទេសធំៗ និងសមាគមអាជីវកម្មដើរតួយ៉ាងសំខាន់ក្នុងវិស័យ វ.ប.ន. ក្នុងនោះរួមមាន តួនាទីជាអ្នកនវានុវត្តន៍ផ្ទើម ជាវិនិយោគិន និងជាអ្នកប្រើប្រាស់បច្ចេកវិទ្យាជាដើម។ រាជរដ្ឋាភិបាលមិនអាចណែនាំវិស័យឯកជនឱ្យវិនិយោគលើសកម្មភាពក្នុងវិស័យ វ.ប.ន. បានទេ ប៉ុន្តែអាចលើកទឹកចិត្តដល់ការវិនិយោគ តាមរយៈការចេញបទប្បញ្ញត្តិនានា ការលើកទឹកចិត្ត និងការបង្កើតលក្ខខណ្ឌអំណោយផលដល់នវានុវត្តន៍ ព្រមទាំងការកសាងហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធសំខាន់ៗដែលលើកស្ទួយដល់វិស័យនេះ។ ម្យ៉ាងទៀត វាក៏ចាំបាច់ដែរក្នុងការពិគ្រោះយោបល់ ក៏ដូចជាសហការជាមួយដៃគូអភិវឌ្ឍន៍អន្តរជាតិដែលអាចគាំទ្រដល់ការអនុវត្តសកម្មភាពពាក់ព័ន្ធនឹងនវានុវត្តន៍ តាមរយៈជំនួយបច្ចេកទេស និងហិរញ្ញវត្ថុ។

ជំពូកបន្តបន្ទាប់ទៀតនឹងរៀបរាប់អំពីគោលដៅ និងលិខិតូបករណ៍សំខាន់ៗក្នុងការអនុវត្តគោលនយោបាយជាតិ វ.ប.ន. និងក្របខ័ណ្ឌពេលវេលាដើម្បីអនុវត្តអាទិភាពដែលបានកំណត់។

# ៣. សសរស្តម្ភទាំង ៥ នៃផែនទីបង្ហាញផ្លូវ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍កម្ពុជា ២០៣០

## ៣.១ ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ជាតិ

### *៣.១.១ គោលដៅគោលនយោបាយ*

កម្ពុជាបានដាក់ចេញនូវគោលដៅប្រកបដោយមហិច្ឆតាខ្ពស់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៤ និងចក្ខុវិស័យឆ្នាំ២០៥០។

ខាងក្រោមនេះគឺជាគោលដៅដែលបានដាក់ចេញដើម្បីកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ជាតិ (NIS) និងដើម្បីវាស់វែងវឌ្ឍនភាព៖

- ក្រសួងឧ.វ.ប.ន. មានតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងសម្របសម្រួលលើគោលនយោបាយស្តីពី វ.ប.ន.។ ទន្ទឹមគ្នានេះ ក.ជ.វ.ប.ន. មានតួនាទីកំណត់ទិសដៅគោលនយោបាយជាតិស្តីពី វ.ប.ន.។
- ការវិនិយោគរួមគ្នារវាងស្ថាប័នសាធារណៈ និងឯកជនទៅលើវិស័យ វ.ប.ន. ត្រូវមានចំនួន ១% នៃផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) នៅឆ្នាំ២០៣០។ ការវិនិយោគពីសាធារណៈលើវិស័យ វ.ប.ន. ត្រូវមានចំនួន ០,៥% នៃផ.ស.ស. នៅឆ្នាំ២០៣០។
- ហិរញ្ញប្បទានសាធារណៈសម្រាប់សកម្មភាពស្រាវជ្រាវ និងនវានុវត្តន៍ ផ្តោតសំខាន់ទៅលើការឈានទៅសម្រេចសមិទ្ធផលនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក៏ដូចជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពថ្នាក់ជាតិនៅឆ្នាំ២០៣០ រួមមាន គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) សមាហរណកម្មខ្សែច្រវ៉ាក់តម្លៃតំបន់។

### *៣.១.២ ពិពណ៌នាអំពីសកម្មភាពនិងលិខិតូបករណ៍គោលនយោបាយ*

សកម្មភាពនិងលិខិតូបករណ៍ដែលបានដាក់ចេញដើម្បីឆ្លើយតបទៅនឹងគោលដៅគោលនយោបាយខាងលើ ត្រូវបានកំណត់ជាបីទិសដៅដូចមានរៀបរាប់នៅក្នុងតារាងទី ១។

*តារាងទី ១៖ ការកែលម្អអភិបាលកិច្ចនៃប្រព័ន្ធនវានុវត្តន៍ជាតិ*

| | |
|---|---|
| ការកំណត់តួនាទីរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តគោលនយោបាយជាតិស្តីពី វ.ប.ន. | ១. ប្រគល់តួនាទីជូនក្រសួង ឧ.វ.ប.ន. ដើម្បីដឹកនាំការតាក់តែង និងត្រួតពិនិត្យ តាមដានគោលនយោបាយជាតិស្តីពី វ.ប.ន. ក៏ដូចជាកំណត់ឱ្យបានច្បាស់នូវតួនាទី និងការទទួលខុសត្រូវរបស់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធទាំងឡាយ។<br>២. ប្រគល់តួនាទីជូន ក.ជ.វ.ប.ន. ដើម្បីអនុម័តទិសដៅគោលនយោបាយជាតិស្តីពី វ.ប.ន.។ |

| | |
|---|---|
| | ៣. ចូលរួមកំណត់ផែនទីបង្ហាញផ្លូវតាមវិស័យដែលទាក់ទងនឹង វ.ប.ន. ជាមួយបណ្ដាក្រសួងស្ថាប័នពាក់ព័ន្ធ។<br>៤. ចូលរួមការសន្ទនាជាមួយបណ្ដាប្រទេសមានបច្ចេកវិទ្យាខ្ពស់។ |
| ពង្រឹងការយល់ដឹង និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយជាតិ វ.ប.ន. | ៥. រៀបចំផែនការបណ្ដុះបណ្ដាលដល់មន្ត្រីក្រសួង ឧ.វ.ប.ន. ដើម្បីដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យតាមដានការអនុវត្តគោលនយោបាយជាតិ វ.ប.ន.។<br>៦. ធ្វើការលើកកម្ពស់ការយល់ដឹងនៅក្នុងស្ថាប័នរាជរដ្ឋាភិបាល អំពី វ.ប.ន. និងគោលដៅនៃគោលនយោបាយជាតិ វ.ប.ន.។<br>៧. រៀបចំផែនការថវិការបស់រាជរដ្ឋាភិបាលសម្រាប់ការវិនិយោគលើវិស័យ វ.ប.ន. ។ |
| ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវដើម្បីរៀបចំគោលនយោបាយដែលផ្អែកលើទទ្បីករណ៍ | ៨. បង្កើតប្រព័ន្ធត្រួតពិនិត្យនិងវាយតម្លៃ។<br>៩. សហការជាមួយវិទ្យាស្ថានជាតិស្ថិតិដើម្បីស្ទង់មតិ សំដៅវាយតម្លៃសមិទ្ធនវានុវត្តន៍របស់សហគ្រាស។<br>១០. ពិនិត្យឡើងវិញលើការអនុវត្តផែនទីបង្ហាញផ្លូវរៀងរាល់ ៣ ទៅ ៤ ឆ្នាំម្ដង។ |

## ការកំណត់តួនាទីរបស់ភាគីពាក់ព័ន្ធទាំងអស់ក្នុងការអនុវត្តគោលនយោបាយជាតិ វ.ប.ន.

ពិតណាស់ ការកំណត់និយមន័យនវានុវត្តន៍ និងព្រំដែននៃប្រព័ន្ធនវានុវត្តន៍ឱ្យបានច្បាស់លាស់គឺជាកិច្ចការដ៏លំបាកមួយ។ គោលនយោបាយជាតិ វ.ប.ន. ប្រាកដណាស់ក៏ត្រូវមានអន្តរកម្ម ក៏ដូចជាបំពេញបន្ថែមឱ្យគោលនយោបាយផ្សេងទៀត ដែលផ្ដោតសំខាន់លើទីផ្សារដែលបានកំណត់ជាអាទិភាព ដូចជាទូរគមនាគមន៍ ថាមពល សុខាភិបាល និងកម្មន្តសាល ឬក៏ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ដូចជា ការវិនិយោគ ផ្ទាល់ពីបរទេស ការប្រកួតប្រជែង ប្រក្រតីនីយកម្ម ដើម្បីសម្រេចបាននូវការធ្វើសំយោគសំដៅដល់ភាពរួមបញ្ចូល និងស៊ីចង្វាក់គ្នា។ ហេតុដូច្នេះហើយ អភិបាលកិច្ចល្អ គឺជាគន្លឹះក្នុងការផ្សព្វផ្សាយព័ត៌មានស្ដីអំពីចរិតលក្ខណៈ និងសារៈសំខាន់នៃនវានុវត្តន៍ ក៏ដូចជាការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងទាំងអស់ក្នុងការលើកកម្ពស់សមិទ្ធនវានុវត្តន៍របស់ជាតិ។

នៅក្នុងរយៈពេលខ្លី រាជរដ្ឋាភិបាលត្រូវខិតខំអនុវត្តសកម្មភាពដូចខាងក្រោម៖

- ប្រគល់តួនាទីដឹកនាំជូនក្រសួង ឧ.វ.ប.ន. ដើម្បីតាក់តែង និងត្រួតពិនិត្យតាមដានគោលនយោបាយជាតិ វ.ប.ន. ក៏ដូចជាកំណត់តួនាទីឱ្យបានច្បាស់រវាងក្រសួង ឧ.វ.ប.ន. និងក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងឡាយ ក្នុងនោះក៏ត្រូវកំណត់តួនាទីឱ្យបានច្បាស់លាស់ដល់ក្រសួង-ស្ថាប័នដែលមានរួចទៅហើយនូវគោលនយោបាយ និងកម្មវិធីគាំទ្រដល់ការអភិវឌ្ឍស្នែម។ ក្រសួង ឧ.វ.ប.ន. ក៏ត្រូវមានតួនាទីដឹកនាំកិច្ចសម្របសម្រួលការងាររបស់រាជរដ្ឋាភិបាលសំដៅគាំទ្រដល់វិស័យ វ.ប.ន. និងត្រូវចូលរួមនៅក្នុងក្រុម

ការងារគោលនយោបាយតាមវិស័យទាំងឡាយណាដែលមានទំនាក់ទំនងជាមួយគោលនយោបាយនិងប្រព័ន្ធ វ.ប.ន.។

- ធានាឱ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាព តាមរយៈការបង្កើតអង្គភាពនវានុវត្តន៍ និង/ឬក្រុមការងារអន្តរក្រសួងរួមមាន៖ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងផែនការ។
- ប្រគល់តួនាទីជូន ក.ជ.វ.ប.ន. ដើម្បីពិភាក្សានិងអនុម័តទិសដៅគោលនយោបាយជាតិ វ.ប.ន. និងរបៀបវារៈស្រាវជ្រាវជាតិ (សូមមើលផ្នែកទី ៣.៣)។
- សហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីកំណត់ផែនទីបង្ហាញផ្លូវតាមវិស័យទាក់ទងនឹង វ.ប.ន. ជាពិសេសនៅក្នុងវិស័យកសិកម្មនិងកសិផលិតកម្ម បច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន (ICT) ការអប់រំ ការស្រាវជ្រាវ ពាណិជ្ជកម្ម សុខាភិបាលនិងជីវឱសថ បច្ចេកវិទ្យានិងវិស្វកម្មទំនើបក្នុងវិស័យកម្មន្តសាល វិទ្យាសាស្ត្រនិងវិស្វកម្មរូបធាតុ ការទូតវិទ្យាសាស្ត្រ ព្រមទាំងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យ វ.ប.ន.។
- ចូលរួមកិច្ចសន្ទនា និងការទូតវិទ្យាសាស្ត្រជាមួយបណ្តាប្រទេសមានបច្ចេកវិទ្យាខ្ពស់ ដើម្បីផ្សារភ្ជាប់ទំនាក់ទំនងជិតស្និទ្ធ ក៏ដូចជាធានាឱ្យមានកិច្ចសហប្រតិបត្តិការបន្ថែមទៀតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ការស្រាវជ្រាវ និងវិស័យឯកជន

## ពង្រឹងការយល់ដឹង និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយជាតិ វ.ប.ន.

ដើម្បីកសាងគោលនយោបាយដែលមានលក្ខណៈប្រទាក់ក្រឡាគ្នា ការលើកកម្ពស់ការយល់ដឹងរបស់មន្ត្រីរាជរដ្ឋាភិបាលអំពីនវានុវត្តន៍ និងទំនាក់ទំនងរវាងនវានុវត្តន៍ជាមួយនឹងគោលនយោបាយដទៃទៀត គឺជាកិច្ចការដ៏សំខាន់មួយ។ ការអភិវឌ្ឍជំនាញ ដើម្បីកសាង និងអនុវត្តគោលនយោបាយនវានុវត្តន៍ និងគោលនយោបាយពាក់ព័ន្ធផ្សេងទៀត ជាកិច្ចការចាំបាច់ដែលត្រូវយកចិត្តទុកដាក់។ ដើម្បីឈានទៅសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលត្រូវអនុវត្តសកម្មភាពដូចខាងក្រោម៖

- រៀបចំផែនការបណ្តុះបណ្តាលមន្ត្រីក្រសួង ឧ.វ.ប.ន. ដើម្បីពង្រឹងសមត្ថភាពក្នុងការដឹកនាំ សម្របសម្រួល និងត្រួតពិនិត្យតាមដានការអនុវត្តគោលនយោបាយជាតិ វ.ប.ន.។
- រៀបចំសកម្មភាពលើកកម្ពស់ការយល់ដឹងអំពី វ.ប.ន. ក៏ដូចជាគោលនយោបាយជាតិ វ.ប.ន. និងផែនទីបង្ហាញផ្លូវ វ.ប.ន. នៅក្នុងជួររាជរដ្ឋាភិបាល។ សកម្មភាពទាំងនោះអាចជាការរួមគ្នាកសាងលិខិតូបករណ៍គោលនយោបាយ ឬបង្កើតយុទ្ធនាការផ្សព្វផ្សាយ វ.ប.ន. ដោយចាប់ផ្តើមពីការផ្លាស់ប្តូរយោបល់គ្នាឱ្យបានទូលំទូលាយជុំវិញគោលនយោបាយជាតិ វ.ប.ន.។ សកម្មភាពដំបូងគប្បីផ្តោតលើតួអង្គពាក់ព័ន្ធជាអាទិ៍៖ អ្នកនយោបាយនិងមន្ត្រីរាជរដ្ឋាភិបាល គ្រូបង្រៀន សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ សមាគមអាជីវកម្ម អង្គការ ព្រមទាំងស្ថាប័នអន្តរការីផ្សេងៗ។

- រៀបចំផែនការថវិការបស់រាជរដ្ឋាភិបាលសម្រាប់ការវិនិយោគលើវិស័យ វ.ប.ន. ដោយផ្តោតលើសកម្មភាពសំខាន់ៗដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវនេះ ក៏ដូចជាផ្តោតលើស្ថាប័នឈានមុខគេក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកទេស។

## ការត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ ដើម្បីផ្តល់ជាទឡ្ហីករណ៍បន្ថែមសម្រាប់អ្នកតាក់តែងគោលនយោបាយក្នុងការកសាងគោលនយោបាយឱ្យមានប្រសិទ្ធភាព និងកែសម្រួលតាមការចាំបាច់

ការត្រួតពិនិត្យ និងវាយតម្លៃគឺជាគន្លឹះដ៏សំខាន់មួយក្នុងការកំណត់ទិសដៅនៃការអនុវត្តគោលយោបាយ។ បច្ចុប្បន្ន នៅកម្ពុជា ទិន្នន័យស្តីពីសកម្មភាព សមិទ្ធកម្ម ព្រមទាំងផលប៉ះពាល់នានាទាក់ទិននឹងវិស័យ វ.ប.ន. គឺនៅមានកម្រិតនៅឡើយ។ ដូច្នេះ ការវាស់វែងអំពីវឌ្ឍនភាពនៃការអនុវត្តសកម្មភាពដែលមានចែងនៅក្នុងផែនទីបង្ហាញផ្លូវ វ.ប.ន. គឺជាការងារដ៏លំបាកមួយនាពេលនេះ។ម្យ៉ាងទៀត ការធ្វើឱ្យប្រសើរឡើងនូវការប្រមូលទិន្នន័យដែលទាក់ទងនឹងសកម្មភាព វ.ប.ន. ព្រមទាំងផលប៉ះពាល់ដែលកើតមានឡើងគឺជាកិច្ចការដែលត្រូវធ្វើ ដើម្បីអាចវាយតម្លៃលើវឌ្ឍភាពជាបន្តបន្ទាប់ និងដើម្បីបង្កើតចំណេះដឹងក្នុងការវាយតម្លៃថាតើវិធានការគោលនយោបាយដែលបានត្រូវយកមកប្រើ និងអនុវត្តន៍មានប្រសិទ្ធភាពដែរឬទេ។ ក្នុងបរិការណ៍នេះ ក្រសួង ឧ.វ.ប.ន. នឹងអនុវត្តសកម្មភាពដូចខាងក្រោម៖

- ដាក់ឱ្យប្រើប្រាស់ប្រព័ន្ធត្រួតពិនិត្យតាមដានគោលដៅនៃគោលនយោបាយសំខាន់ៗដែលមាននៅក្នុងផែនទីបង្ហាញផ្លូវ ព្រមទាំងសូចនាករនៃការអនុវត្តសកម្មភាពផ្សេងៗ និងត្រូវធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីវឌ្ឍនភាព និងសមិទ្ធកម្ម ដើម្បីដាក់ជូន ក.ជ.វ.ប.ន. ពិភាក្សានិងពិគ្រោះយោបល់គ្នា។
- បង្កើតភាពជាដៃគូរវាង ក.ឧ.វ.ប.ន. និងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការដើម្បីផ្តល់ទិន្នន័យនិងស្ថិតិបន្ថែមអំពីសមិទ្ធនវានុវត្តន៍នៅតាមវិស័យរដ្ឋ និងឯកជន ដូចជាការសិក្សាអង្កេតអំពីកម្រិតនវានុវត្តន៍របស់សហគ្រាសជារៀងរាល់ ៣ ឬ ៤ ឆ្នាំម្តង ដោយប្រើប្រាស់វិធានស្តង់ដារអន្តរជាតិ[3]។
- វាយតម្លៃ និងត្រួតពិនិត្យផែនទីបង្ហាញផ្លូវនេះឡើងវិញជារៀងរាល់ ៣ ឬ ៤ ឆ្នាំម្តង និងកែសម្រួលខ្លឹមសារតាមការចាំបាច់។ ការវាយតម្លៃទៅលើផែនទីបង្ហាញផ្លូវនេះនឹងត្រូវបានធ្វើឡើងជារៀងរាល់ ៣ ឬ ៤ ឆ្នាំម្តង ដោយចាប់ផ្តើមពីឆ្នាំ២០២៣ ដើម្បីកែសម្រួលគោលនយោបាយ និងសកម្មភាពមួយចំនួនសំដៅបង្កើនប្រសិទ្ធភាព និង/ឬ ប្រសិទ្ធផល និងដើម្បីធ្វើឱ្យប្រាកដថា ការអភិវឌ្ឍវិស័យផ្សេងទៀតត្រូវបានគិតគូរ។

---

[3] ស្រដៀងគ្នាទៅនឹង "ការស្ទង់មតិនវានុវត្តន៍សហគមន៍" របស់ Eurostat ឬ "ការស្ទង់មតិការស្រាវជ្រាវនិងអភិវឌ្ឍន៍ និងនវានុវត្តន៍ពាណិជ្ជកម្ម" ដែលរៀបចំឡើងដោយមូលនិធិវិទ្យាសាស្ត្រជាតិនៅសហរដ្ឋអាមេរិក។ វិទ្យាស្ថានស្ថិតិរបស់ UNESCO ក៏មានផ្តល់ការណែនាំអំពីវិធីស្ទង់មតិលើការស្រាវជ្រាវនិងអភិវឌ្ឍន៍។ សូមអានបន្ថែម៖ http://uis.unesco.org/sites/default/files/documents/guide-to-conducting-an-rd-survey-for-countries-starting-to-measure-research-and-experimental-development-2014-en.pdf.

### ៣.១.៣ គោលនយោបាយចម្រុះ

តារាងទី ២ ផ្តល់ព័ត៌មានសង្ខេបអំពីបណ្តុំវិធានការដែលត្រូវអនុវត្ត។

*តារាងទី ២៖ គោលនយោបាយចម្រុះ៖ អភិបាលកិច្ច*

| សសរស្តម្ភ | ពេលវេលា | លិខិតូបករណ៍គតិយុត្ត | សកម្មភាព | លិខិតូបករណ៍ហិរញ្ញវត្ថុ |
|---|---|---|---|---|
| កែលម្អអភិបាលកិច្ចទូទៅនៃប្រព័ន្ធនវានុវត្តន៍ជាតិ | ២០២១-២០២២ | • ប្រគល់តួនាទីជូនក្រសួង ឧ.វ.ប.ន. ក្នុងការដឹកនាំសម្របសម្រួល និងកំណត់តួនាទីឱ្យបានច្បាស់លាស់ដល់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធទាំងឡាយ។ បង្កើតអង្គភាពនវានុវត្តន៍ និងក្រុមការងារអន្តរក្រសួង នៅតាមក្រសួងស្ថាប័នពាក់ព័ន្ធ ជាអាទិ៍៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រសួងផែនការ<br>• សហការរៀបចំផែនការនវានុវត្តន៍ជាតិតាមវិស័យ ដូចជា វិស័យបច្ចេកវិទ្យាទំនាក់ទំនងនិងព័ត៌មាន ជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ វិស័យកសិកម្ម ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ វិស័យសុខាភិបាល ជាមួយក្រសួងសុខាភិបាល វិស័យការទូតវិទ្យាសាស្ត្រ និងកិច្ចសហប្រតិបត្តិការអន្តរជាតិ ជាមួយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ<br>• ប្រគល់តួនាទីជូន ក.ជ.វ.ប.ន. ដើម្បីពិភាក្សានិងអនុម័តទិសដៅគោលនយោបាយជាតិ វ.ប.ន.<br>• រៀបចំផែនការបណ្តុះបណ្តាលដល់មន្ត្រីក្រសួង ឧ.វ.ប.ន. | • លើកកម្ពស់ការដឹកនាំក្នុងការសម្របសម្រួលតួអង្គនានានៅក្នុងប្រព័ន្ធ វ.ប.ន.<br>• បណ្តុះបណ្តាលមន្ត្រីក្រសួង ឧ.វ.ប.ន. លើការតាក់តែងគោលនយោបាយ វ.ប.ន. និងត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ វ.ប.ន.<br>• ធ្វើយុទ្ធនាការផ្សព្វផ្សាយ វ.ប.ន. និងគោលនយោបាយជាតិ វ.ប.ន. ព្រមទាំងផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០<br>• ពង្រឹងស្ថាប័នប្រមូលទិន្នន័យ វ.ប.ន. ដើម្បីបង្កើតគោលនយោបាយ «អង្គភាពត្រួតពិនិត្យ និងវាយតម្លៃ» និងបង្កើតភាពជាដៃគូជាមួយវិទ្យាស្ថានជាតិស្ថិតិ<br>• ធ្វើការសិក្សាអង្កេត កម្រិតនវានុវត្តន៍របស់សហគ្រាស ដោយយកគំរូតាមការសិក្សាអង្កេតនវានុវត្តន៍សហគមន៍ ឬធនាគារពិភពលោក រៀងរាល់ ៣ ឆ្នាំម្តង | • រៀបចំផែនការថវិការបស់រាជរដ្ឋាភិបាលសម្រាប់ការវិនិយោគក្នុងវិស័យ វ.ប.ន. |

| | | | | |
|---|---|---|---|---|
| | | • ចូលរួមកិច្ចសន្ទនា និងការទូតវិទ្យាសាស្ត្រ ជាមួយបណ្ដាប្រទេសមានបច្ចេកវិទ្យាខ្ពស់ | | |
| | ២០២៣-២០៣០ | • សហការរៀបចំផែនការនវានុវត្តន៍ជាតិតាមវិស័យផ្សេងៗ<br>• បន្តកែលម្អការប្រមូលទិន្នន័យ វ.ប.ន. សម្រាប់ការរៀបចំ បង្កើតគោលនយោបាយ<br>• វាយតម្លៃផែនទីបង្ហាញផ្លូវនេះរៀងរាល់ ៣ ឆ្នាំម្តង និងកែសម្រួលតាមការចាំបាច់ | • បន្តលើកកម្ពស់ វ.ប.ន.<br>• បន្តបណ្តុះបណ្តាលមន្ត្រីក្រសួង ឧ.វ.ប.ន. លើការតាក់តែងគោលនយោបាយ និងការត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ វ.ប.ន. | |

## ៣.២ ការកសាងមូលធនមនុស្សផ្នែក វ.ប.ន.

### *៣.២.១ គោលដៅគោលនយោបាយ*

ខណៈដែលប្រទេសកម្ពុជាមានគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ចផ្អែកលើឧស្សាហកម្ម និងមានមហិច្ឆតាប្រែក្លាយខ្លួនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ តម្រូវការធនធានមនុស្សប្រកបដោយគុណភាពនៅក្នុងស្ទែមមានសារៈសំខាន់ខ្លាំងណាស់។ ការលើកកម្ពស់ជំនាញនៅក្នុងចំណោមកម្លាំងពលកម្មដែលមានស្រាប់ ក៏ដូចជាកម្លាំងពលកម្មថ្មីដែលធ្វើការក្នុងវិស័យនេះគឺជាកិច្ចការដ៏សំខាន់មួយ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស ជាពិសេសនៅក្នុងវិស័យដែលពឹងផ្អែកខ្លាំងលើបច្ចេកវិទ្យា ដែលអាចបង្កើតការងារក្នុងស្រុកជាមួយនឹងការបង្កើនតម្លៃបន្ថែម (សូមមើលផ្នែក ៣.៥) និងដើម្បីនាំចេញទំនិញ ក៏ដូចជាសេវាកម្មទៅកាន់ទីផ្សារអន្តរជាតិ។ ក្នុងន័យនេះ ការអប់រំនិងការបង្កើតធនធានមនុស្សដែលមានជំនាញកម្រិតខ្ពស់ក្នុងស្ទែមគឺជាកិច្ចការដែលត្រូវអនុវត្ត។ ទោះជាយ៉ាងនេះក្ដី គេសង្កេតឃើញមានអតុល្យភាពរវាងការចុះឈ្មោះចូលរៀនក្នុងជំនាញស្ទែមនិងមិនមែនស្ទែមនៅថ្នាក់ឧត្តមសិក្សា។ តួយ៉ាង នៅប្រទេសកម្ពុជា មានការចុះឈ្មោះចូលរៀនយ៉ាងច្រើននៅតាមគ្រឹះស្ថានឧត្តមសិក្សាដើម្បីសិក្សាលើមុខជំនាញមិនមែនស្ទែម ដូចជា ផ្នែកអាជីវកម្ម ការគ្រប់គ្រង សេដ្ឋកិច្ច មនុស្សសាស្ត្រ និងគណនេយ្យ ដែលជាហេតុនាំឱ្យមានធនធានមនុស្សក្នុងជំនាញមិនមែនស្ទែមច្រើនហួសពីតម្រូវការទីផ្សារ។ ដូច្នេះ ដើម្បីប្រើប្រាស់ អភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យាទៅក្នុងទីផ្សារបាន កិច្ចការចាំបាច់ដែលត្រូវធ្វើគឺការបណ្ដុះបណ្ដាលអ្នកជំនាញបច្ចេកទេសនៅតាមស្ថាប័នអប់រំ បណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ ហៅថា ធីវេត (TVET) បន្ថែមពីលើធនធានវិស្វករ និងអ្នកវិទ្យាសាស្ត្រ ដែលមានស្រាប់។

ក្នុងរយៈពេលមធ្យមនិងវែង តម្រូវការធនធានមនុស្សដែលមានជំនាញផ្នែក ការបង្រៀន ការស្រាវជ្រាវនិងនវានុវត្តន៍នឹងមានការកើនឡើង។ ស្ថិតក្នុងបរិការណ៍នេះ ដើម្បីធានាឱ្យមានជំនាញទាំងនេះ គេត្រូវតែអនុវត្តសកម្មភាពដើម្បីលើកកម្ពស់វប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គម សំដៅកសាងធនធានមនុស្សរឹងមាំនៅក្នុងជំនាញស្ទែម និងពង្រឹងការងារបង្រៀនស្ទែមតាមរយៈគ្រឹះស្ថានធីវេត និងគ្រឹះស្ថានឧត្តមសិក្សានានា។ គោលនយោបាយ សម្រាប់ការអប់រំ និងបណ្ដុះបណ្ដាលចាប់ពីថ្នាក់សិក្សាមូលដ្ឋាន រហូតដល់ថ្នាក់ឧត្តមសិក្សា គឺត្រូវមានការចូលរួមសហការគ្នាក្នុងចំណោមក្រសួងនានាដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ និងក្រសួង ឧ.វ.ប.ន.។

ខាងក្រោមនេះគឺជាគោលដៅដែលបានដាក់ចេញដើម្បីលើកកម្ពស់វប្បធម៌វិទ្យាសាស្ត្រ បង្កើនការផ្ទេរចំណេះដឹងជំនាញស្ទែម និងដើម្បីវាស់វែងវឌ្ឍនភាព៖

- បង្កើនសមាមាត្រនៃចំនួននិស្សិតបញ្ចប់ការសិក្សាក្នុងជំនាញស្ទែមយ៉ាងហោចណាស់ ៥០% នៅឆ្នាំ ២០៣០។[4]

---

[4] យោងស្ថិតិដែលចងក្រងដោយនាយកដ្ឋានឧត្តមសិក្សាឆ្នាំ២០១០-២០១៦ MOEYS (២០១៦) នៅក្នុងឆ្នាំ២០១៦ មាននិស្សិត ២០% (ឬ ៤៤ ០០០នាក់) នៃនិស្សិតបញ្ចប់ការសិក្សាចំនួន ២២២ ០០០ ពីគ្រឹះស្ថានឧត្តមសិក្សាតែប៉ុណ្ណោះ ដែលបានសិក្សាជំនាញ

- យ៉ាងហោចណាស់ ៤០% នៃនិស្សិតបញ្ចប់ការសិក្សាក្នុងស្ទែមជាស្ត្រី នៅឆ្នាំ២០៣០។[5]
- កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត នឹងត្រូវរៀបចំឡើងដោយមានការសហការជាមួយវិស័យឯកជន នៅមុនឆ្នាំ២០២៤។
- វេទិកាបច្ចេកវិទ្យា ជាអាទិ៍៖ មន្ទីរពិសោធន៍ដែលមានសម្ភារ ដូចជា រ៉ូបូត សិនស័រ រូបថត (Imagery) នឹងត្រូវបង្កើតឡើងនៅតាមសាកលវិទ្យាល័យ និងគ្រឹះស្ថានជីវិត ក្នុងគោលបំណងអប់រំ នៅឆ្នាំ២០២៤ និងមាននិស្សិតប្រើប្រាស់ចំនួន ៥០០ នាក់។
- សារមន្ទីរវិទ្យាសាស្ត្រចំនួនពីរ ឬជាមជ្ឈមណ្ឌលអប់រំវិទ្យាសាស្ត្រ នឹងមានតួនាទីលើកកម្ពស់ការអប់រំវិទ្យាសាស្ត្រដល់កុមារនៅទូទាំងប្រទេសនៅឆ្នាំ២០២៣ ដោយសារមន្ទីរមួយមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញ នៅឆ្នាំ២០២៣។
- រៀបចំព្រឹត្តិការណ៍ចំនួន ២០ថ្ងៃ ទាក់ទិននឹងនវានុវត្តន៍ ឬ វេទិកានវានុវត្តន៍ចំនួន ២០ ត្រឹមឆ្នាំ២០៣០ ដើម្បីបញ្ជ្រាបព័ត៌មានដល់ប្រជាជន ១០ ០០០ នាក់ សហគ្រាសធុនតូច និងមធ្យមចំនួន ៥ ០០០ និងមន្ត្រីរាជការចំនួន ១ ០០០ នាក់។
- បណ្ណាល័យវិទ្យាសាស្ត្រចំនួនបី នឹងបើកឱ្យដំណើរការនៅក្នុងប្រទេសនៅត្រឹមឆ្នាំ២០៣០ ដោយបណ្ណាល័យមួយមានទីតាំងស្ថិតនៅក្នុងរាជធានីភ្នំពេញត្រឹមឆ្នាំ២០២៣។

### *៣.២.២ ពិពណ៌នាអំពីសកម្មភាពនិងលិខិតូបករណ៍គោលនយោបាយ*

ដើម្បីសម្រេចគោលដៅខាងលើ សកម្មភាពនិងលិខិតូបករណ៍គោលនយោបាយសំខាន់ៗ ត្រូវបានដាក់ចេញ ដោយផ្តោតលើទិសដៅចំនួន ៤ រួមមាន លើកកម្ពស់ការត្រៀមលក្ខណៈក្នុងវិស័យបច្ចេកវិទ្យាសម្រាប់យុវជន និងសង្គម និងផ្តល់ជំនាញដែលចាំបាច់ដើម្បីប្រើប្រាស់ និងអភិវឌ្ឍបច្ចេកវិទ្យា (តារាងទី៣)។

*តារាងទី ៣៖ កសាងធនធានមនុស្សក្នុងវិស័យ វ.ប.ន.*

| | |
|---|---|
| លើកកម្ពស់វប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គម | ១. ជំរុញឱ្យមានការតាំងពិព័រណ៍វិទ្យាសាស្ត្រ មហោស្រពវិទ្យាសាស្ត្រ ការបើកឱ្យចូលទស្សនាដោយសេរីនៅតាមសាកលវិទ្យាល័យ យុទ្ធនាការតាមប្រព័ន្ធទំនាក់ទំនងសង្គម ការប្រកួតប្រជែងផ្នែកវិទ្យាសាស្ត្រ សារមន្ទីរវិទ្យាសាស្ត្រ ដោយមានការចូលរួមរបស់វិស័យឯកជន ព្រមទាំងសម្របសម្រួលឱ្យមានកម្មវិធីជាម៉ូឌែលគំរូ និងគម្រោងទាក់ទិននឹង វ.ប.ន. ដើម្បីឱ្យយុវជនយកគំរូតាម។ |

ស្ទែម។ ប្រភព៖ Sovansophal, Kao & Shimizu, Kinya. (2020). A Review on STEM Enrolment in Higher Education of Cambodia: Current Status, Issues, and Implications of Initiatives. 26. 123-134.

[5] នៅឆ្នាំ២០១៦ និស្សិតបញ្ចប់ការសិក្សាជំនាញស្ទែមចំនួន ១៤% គឺជាស្ត្រី ខណៈបុរសមានចំនួន ៨៤%។

| | |
|---|---|
| លើកកម្ពស់ការត្រៀមលក្ខណៈក្នុងវិស័យបច្ចេកវិទ្យាសម្រាប់យុវជននៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា | ២. បញ្ចូលមុខវិជ្ជាទាក់ទិននឹងវិទ្យាសាស្ត្រ ឌីជីថល និងសហគ្រិនភាព ទៅក្នុងកម្មវិធីសិក្សាថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។<br>៣. រៀបចំវគ្គបណ្តុះបណ្តាលដល់គ្រូបង្រៀនស្តីពីការបង្រៀនស្ទែម ដោយប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសបង្រៀនប្រកបដោយគំនិតនវានុវត្តន៍។<br>៤. ផ្តល់កុំព្យូទ័រដល់សិស្សានុសិស្សសម្រាប់សិក្សា។ |
| បង្កើនភាពទាក់ទាញនៅក្នុងកម្មវិធីសិក្សាជំនាញស្ទែម និងបង្កើនចំនួននិស្សិតបញ្ចប់ការសិក្សាជំនាញនេះនៅថ្នាក់ឧត្តមសិក្សា | ៥. បង្កើតកម្មវិធីសិក្សាទាក់ទងជាមួយនវានុវត្តន៍ និងសហគ្រិនភាពសម្រាប់ថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។<br>៦. ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសបង្រៀនស្ទែម ប្រកបដោយគំនិតនវានុវត្តន៍។<br>៧. បង្កើតឱ្យមានការប្រកួតប្រជែងក្នុងចំណោមអ្នកវិទ្យាសាស្ត្រវ័យក្មេងក្នុងជំនាញស្ទែម ដូចជា ការប្រកួតប្រជែងលើសហគ្រិនភាព និងនវានុវត្តន៍។<br>៨.ពង្រីកបណ្តាញនិងកិច្ចសហការអន្តរជាតិឱ្យបានទូលំទូលាយក្នុងជំនាញស្ទែម ដើម្បីទាក់ទាញអ្នកស្រាវជ្រាវទស្សនកិច្ច (Visiting Researchers)។<br>៩. ជំរុញកម្មវិធីផ្លាស់ប្តូរការសិក្សាក្រៅប្រទេសសម្រាប់និស្សិតជំនាញស្ទែម។<br>១០. ផ្តល់កម្មសិក្សាដល់និស្សិតជំនាញស្ទែមក្នុងវិស័យឧស្សាហកម្ម។<br>១១.បំពាក់ឧបករណ៍ពិសោធន៍ទាន់សម័យដល់សាលារៀន។ |
| ពង្រឹងគុណភាពបង្រៀន និងកិច្ចសហការជាមួយវិស័យឯកជន នៅតាមគ្រឹះស្ថានជីវិត | ១២. អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូឧទ្ទេសនៅតាមគ្រឹះស្ថានជីវិតដោយមានកិច្ចសហការជាមួយស្ថាប័នក្នុងវិស័យឧស្សាហកម្ម។<br>១៣.បញ្ជូននិស្សិតជីវិត ទៅធ្វើកម្មសិក្សានៅតាមបណ្តាស្ថាប័នក្នុងវិស័យឧស្សាហកម្ម។<br>១៤. បំពាក់ឧបករណ៍បច្ចេកទេសទាន់សម័យដែលកំពុងប្រើប្រាស់ដោយវិស័យឯកជននៅតាមគ្រឹះស្ថានជីវិត។<br>១៥.កៀរគរថវិកាសម្រាប់ជួយគាំទ្រដល់គ្រឹះស្ថានជីវិតណាដែលមានស្នាដៃល្អប្រសើរ។ |

## ពង្រឹងវប្បធម៌វិទ្យាសាស្ត្រនៅក្នុងសង្គម

ការកសាងយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នាគប្បីរៀបចំឱ្យបាននៅក្នុងការសិក្សាគ្រប់កម្រិតទាំងអស់ សំដៅលើកកម្ពស់ការយល់ដឹងអំពីអាជីពការងារដែលពាក់ព័ន្ធនឹងវិស័យបច្ចេកវិទ្យាឌីជីថល វិទ្យាសាស្ត្រ និងស្ទែមនៅក្នុងស្រទាប់យុវជននិងក្រុមគ្រួសារ ខណៈគ្រួសាររបស់យុវជនមានឥទ្ធិពលខ្លាំងទៅលើជម្រើសអាជីពការងាររបស់ពួកគេ។ ការកសាងយុទ្ធសាស្ត្រនេះគប្បីមានការសហការគ្នាក្នុងចំណោមក្រសួង-ស្ថាប័នពាក់ព័ន្ធដូចជា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួង ឧ.វ.ប.ន.។ គោលបំណងសំខាន់នៃការកសាងយុទ្ធសាស្ត្រនេះគឺដើម្បីបណ្តុះចំណាប់អារម្មណ៍របស់សិស្ស-និស្សិត ក៏ដូចជាឥរិយាបថវិជ្ជមានចំពោះមុខវិជ្ជាវិទ្យាសាស្ត្រនៅថ្នាក់មធ្យមសិក្សាចំណេះទូទៅ ព្រមទាំងដើម្បីបង្កើនទំនុកចិត្ត និងលើកទឹកចិត្តសិស្ស-និស្សិតទាំងនោះឱ្យបន្តការសិក្សាលើផ្នែកវិទ្យាសាស្ត្រ ឬមុខវិជ្ជាដែលទាក់ទងនឹងស្ទែមនៅថ្នាក់ឧត្តមសិក្សា។

យុទ្ធនាការទ្រង់ទ្រាយធំជាច្រើននឹងត្រូវរៀបចំឡើង ក្នុងគោលបំណងបន្តផ្សព្វផ្សាយ វ.ប.ន. ក្នុងចំណោមអាជីវកម្ម សហគ្រិន យុវជន និងសាធារណជនទូទៅរហូតដល់ឆ្នាំ២០៣០ ដែលរួមមានការតាំងពិព័រណ៍វិទ្យាសាស្ត្រជាលក្ខណៈអន្តរជាតិ មហោស្រពវិទ្យាសាស្ត្រ កម្មវិធីចូលទស្សនាដោយសេរីនៅតាមសាកលវិទ្យាល័យ និងវិទ្យាស្ថានស្រាវជ្រាវ យុទ្ធនាការនៅលើប្រព័ន្ធទំនាក់ទំនងសង្គម ការប្រកួតប្រជែងទាក់ទិននឹងផ្នែកវិទ្យាសាស្ត្រ ការលេងល្បែងកម្សាន្ត និងកម្មវិធីទូរស័ព្ទជាដើម។ ម៉ូឌែលគំរូ និងគម្រោង វ.ប.ន. ទាំងឡាយដែលទាក់ទងនឹងការដោះស្រាយបញ្ហាសង្គម និងបរិស្ថាន នឹងត្រូវបានផ្សព្វផ្សាយជាសាធារណៈ ដើម្បីផ្តល់ជាឧទាហរណ៍ជាក់ស្តែងដល់យុវជនឱ្យយល់ពីមូលហេតុ ដែលជំរុញទឹកចិត្តឱ្យពួកគេចាប់យកអាជីពនៅក្នុងជំនាញស្ទែម។

បន្ថែមទៀតនោះ សារមន្ទីរនិងបណ្ណាល័យវិទ្យាសាស្ត្រ នឹងត្រូវបានបង្កើតឡើងដើម្បីបង្កើនការលើកកម្ពស់ជំនាញស្ទែមក្នុងចំណោមសាធារណជនទូទៅ និងបង្កើនការទទួលបានចំណេះដឹងសម្រាប់អ្នកមានវិជ្ជាជីវៈ។

## បង្កើនការត្រៀមលក្ខណៈក្នុងវិស័យបច្ចេកវិទ្យាសម្រាប់យុវជននៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សា

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានរៀបចំសេចក្តីព្រាងគោលនយោបាយមួយចំនួនរួចរាល់ហើយ ក្នុងគោលបំណងលើកកម្ពស់ការតភ្ជាប់ឌីជីថល និងបញ្ចូលស្ទែមទៅក្នុងកម្មវិធី សិក្សានៅកម្រិតបឋមសិក្សា និងមធ្យមសិក្សា។ ទន្ទឹមគ្នានេះ សូចនាករសម្រាប់តាមដានលើការអនុវត្តគោលនយោបាយទាំងនេះក៏ត្រូវរៀបចំរួចរាល់ដែរហើយ។ ក្រសួង ឧ.វ.ប.ន. នឹងសហការត្រួតពិនិត្យតាមដានការអនុវត្ត គោលនយោបាយទាំងនេះ។ ទោះជាយ៉ាងនេះក្តី ដើម្បីបង្កើនការត្រៀមលក្ខណៈនៅក្នុងវិស័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់យុវជននៅសាលារៀន គេត្រូវអនុវត្តសកម្មភាពបន្ថែមដូចជា៖

- ដាក់បញ្ចូលកម្មវិធីសិក្សាជាក់លាក់ផ្នែកវិទ្យាសាស្ត្រ ឌីជីថល និងសហគ្រិនភាពទៅក្នុងថ្នាក់បឋមសិក្សា និងមធ្យមសិក្សា។
- ដាក់បញ្ចូលវគ្គបណ្តុះបណ្តាលជាក់លាក់ដល់គ្រូដែលបង្រៀនស្ទែម ដោយប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសបង្រៀនប្រកបដោយគំនិតនវានុវត្តន៍ អន្តរកម្ម ចំណាយតិច និងងាយស្រួលសម្រាប់គ្រូ។

- ផ្តល់កុំព្យូទ័រដល់សិស្សសម្រាប់សិក្សា។

## បង្កើនភាពទាក់ទាញនៅក្នុងកម្មវិធីសិក្សាជំនាញស្ទែមនិងបង្កើនចំនួននិស្សិតបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សា

គោលនយោបាយទាំងឡាយដែលតាក់តែងឡើងដោយ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បាន បញ្ចូលស្ទែមទៅក្នុងកម្មវិធីសិក្សានៅថ្នាក់ឧត្តមសិក្សា។ សកម្មភាពដំបូង ក្រសួង ឧ.វ.ប.ន. នឹងសហការត្រួតពិនិត្យតាមដានការអនុវត្តគោលនយោបាយទាំងនេះ។

សកម្មភាពបន្ទាប់ គឺត្រូវបង្កើនចំនួននិស្សិតបញ្ចប់ការសិក្សានៅថ្នាក់ឧត្តមសិក្សាក្នុងជំនាញស្ទែមដោយៈ

- បញ្ចូលវប្បធម៌វិទ្យាសាស្ត្រនិងនវានុវត្តន៍ទៅក្នុងកម្មវិធីសិក្សានៅថ្នាក់បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។
- ដាក់ឱ្យប្រើប្រាស់វិធីសាស្ត្រនិងបច្ចេកទេសបង្រៀនស្ទែមប្រកបដោយនវានុវត្តន៍ ដូចជា បច្ចេកទេសអន្តរកម្ម និងការអនុវត្តជាក់ស្តែងលើឧបករណ៍ជាដើម។
- លើកកម្ពស់អ្នកវិទ្យាសាស្ត្រវ័យក្មេងតាមរយៈការប្រកួតប្រជែងលើនវានុវត្តន៍ និងសហគ្រិនភាពសម្រាប់និស្សិតផ្នែកស្ទែម និងលើកកម្ពស់កម្មវិធី "និស្សិតឆ្នើមផ្នែកស្ទែម" ប្រចាំឆ្នាំ។
- កសាងបណ្តាញកិច្ចសហការអន្តរជាតិជាមួយវិទ្យាស្ថានស្រាវជ្រាវ និងគ្រឹះស្ថានឧត្តមសិក្សាដែលឈានមុខ សំដៅទាក់ទាញសាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ ដែលមានទេពកោសល្យពីបរទេស ដោយផ្តល់ជូនកញ្ចប់ថវិកាលើកទឹកចិត្តដែលគួរឱ្យទាក់ទាញ (Talents Grants In)។
- សម្របសម្រួលនិងគាំទ្រនិស្សិតកម្ពុជាឱ្យទៅបន្តការសិក្សានៅក្រៅប្រទេស និងរៀបចំការលើកទឹកចិត្តដ៏សមស្រប សម្រាប់ឱ្យនិស្សិតវិលត្រលប់មកប្រទេសកម្ពុជាវិញ ដើម្បីចាប់ផ្តើមអាជីពការងាររបស់ពួកគេ (Talents Grants Out)។
- ផ្តួចផ្តើម និងគាំទ្រឱ្យមានកិច្ចសហការដ៏រឹងមាំបន្ថែមទៀតជាមួយវិស័យឯកជន ដើម្បីរៀបចំបង្កើតកម្មវិធីចុះកម្មសិក្សា និងហ្វឹកហ្វឺនការងារជាប្រព័ន្ធសម្រាប់និស្សិតស្ទែម ព្រមទាំងសហការរៀបចំបង្កើតកម្មវិធីសិក្សាស្ទែមឱ្យឆ្លើយតបទៅនឹងតម្រូវការក្នុងវិស័យឧស្សាហកម្ម (សូមមើលផ្នែក ៣.៤)។
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងឧបករណ៍បច្ចេកទេសទាន់សម័យសម្រាប់ការបង្រៀន និងការរៀន អំពីរបៀបប្រើប្រាស់បច្ចេកវិទ្យារ៉ូបូត សិនស័រ រូបថត និងបច្ចេកវិទ្យាផ្សេងទៀត និងបំពាក់ឧបករណ៍បច្ចេកទេសទាំងនោះនៅតាមសាកលវិទ្យាល័យ។

## ពង្រឹងគុណភាពបង្រៀន និងការផ្សារភ្ជាប់ជាមួយវិស័យឯកជន សម្រាប់ជីវេត

គោលដៅសំខាន់នៅក្នុងផ្នែកនេះគឺការពង្រឹងគ្រឹះស្ថានជីវេត និងកម្មវិធីបណ្តុះបណ្តាលជីវេត ដើម្បីបង្កើនភាពទាក់ទាញកាន់តែខ្លាំង និងការផ្សារភ្ជាប់ជាមួយឧស្សាហកម្ម៖

- អភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលគ្រូឧទ្ទេសសម្រាប់កម្មវិធីជីវេត តួយ៉ាង ការបណ្តុះបណ្តាលអំពីបច្ចេកវិទ្យាកម្មន្តសាលទំនើប ជាអាទិ៍៖ រ៉ូបូត មេកាត្រូនិច អេឡិចត្រូនិច ដើម្បីបង្កើនគុណភាពរបស់គ្រូបង្រៀននៅតាមគ្រឹះស្ថានជីវេត។ កម្មវិធីបែបនេះគប្បីត្រូវបានបង្កើតឡើងដោយមានការសហការជិតស្និទ្ធជាមួយវិស័យឧស្សាហកម្ម និងបញ្ចូលការបណ្តុះបណ្តាលជាក់លាក់នៅក្នុងក្រុមហ៊ុនបច្ចេកវិទ្យា។
- ផ្តួចផ្តើម និងគាំទ្រដល់កិច្ចសហការដ៏រឹងមាំបន្ថែមទៀតជាមួយវិស័យឯកជនដើម្បីស្នើសុំឱ្យមានកម្មវិធីចុះកម្មសិក្សា និងហ្វឹកហ្វឺនជាប្រព័ន្ធដល់និស្សិតផ្នែកជីវេត នៅក្នុងវិស័យឧស្សាហកម្ម ព្រមទាំងដើម្បីសហការរៀបចំបង្កើតកម្មវិធីសិក្សាស្វែមឱ្យឆ្លើយតបនឹងតម្រូវការក្នុងវិស័យឧស្សាហកម្ម (សូមមើលផ្នែក ៣.៤)។
- ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងវេទិកាបច្ចេកវិទ្យាសម្រាប់ការបង្រៀន និងការរៀនពីរបៀបប្រើប្រាស់បច្ចេកវិទ្យារ៉ូបូត សិនស័រ រូបថត និងបច្ចេកវិទ្យាផ្សេងៗ ព្រមទាំងបំពាក់ឧបករណ៍ទាំងនោះនៅតាមគ្រឹះស្ថានជីវេត។ សកម្មភាពនេះនឹងធានាឱ្យបានថា សិស្ស-និស្សិតទទួលបានការអនុវត្តជាក់ស្តែង និងជំនាញដែលទីផ្សារត្រូវការនៅគ្រឹះស្ថានជីវេត។
- កៀរគរថវិកា តួយ៉ាង ពីមូលនិធិអភិវឌ្ឍន៍ជំនាញ ដើម្បីគាំទ្រ បំពាក់ និងលើកកម្ពស់ "គ្រឹះស្ថានជីវេតឆ្នើម" ចំនួន ៥ ដើម្បីបង្កើតចំនួនធនធានដែលមានវិជ្ជាជីវៈក្នុងបរិមាណច្រើន ក៏ដូចជាបង្ហាញពីភាពជាគំរូដល់គ្រឹះស្ថានជីវេតផ្សេងទៀត។

### *៣.២.៣. គោលនយោបាយចម្រុះ*

តារាង ៤ ផ្តល់ព័ត៌មានសង្ខេបអំពីបណ្តុំវិធានការដែលត្រូវអនុវត្ត។

*តារាងទី ៤៖ គោលនយោបាយចម្រុះ៖ ការអប់រំ*

| សសរស្តម្ភ | ពេលវេលា | លិខិតូបករណ៍គតិយុត្ត | លិខិតូបករណ៍សង្គម និងវប្បធម៌ | លិខិតូបករណ៍ហិរញ្ញវត្ថុ |
|---|---|---|---|---|
| កសាងធនធានមនុស្សផ្នែក វ.ប.ន. | ២០២១ - ២០២២ | • សហការត្រួតពិនិត្យតាមដានការអនុវត្តយុទ្ធសាស្ត្រអប់រំទាក់ទងនឹង វ.ប.ន.<br>• សហការត្រួតពិនិត្យតាមដានការបង្កើតការអប់រំឌីជីថលនៅគ្រប់កម្រិត<br>• ដាក់ឱ្យប្រើប្រាស់កម្មវិធីសិក្សា ជាពិសេស | • ជំរុញឱ្យមានសារមន្ទីរវិទ្យាសាស្ត្របណ្ណាល័យ វ.ប.ន. ពិព័រណ៍វិទ្យាសាស្ត្រ ទិវាវិទ្យាសាស្ត្រ កម្មវិធីចូលទស្សនាដោយសេរីនៅតាមសាកលវិទ្យាល័យ យុទ្ធនាការតាមប្រព័ន្ធទំនាក់ទំនងសង្គម ការប្រកួតប្រជែងលើនវានុវត្តន៍ និងសហគ្រិនភាព ព្រមទាំងសម្របសម្រួលឱ្យមានកម្មវិធី | • ផ្តល់ថវិកាសម្រាប់ទិញកំព្យូទ័រជូនសិស្សនៅថ្នាក់ចំណេះទូទៅ។<br>• បង្កើតកម្មវិធីថ្នាក់ជាតិដោយដាក់ឱ្យមានវេទិកាបច្ចេកវិទ្យានៅតាមសាកល |

| | | | | |
|---|---|---|---|---|
| | | ទាក់ទិននឹង ស្ទែមនៅថ្នាក់ចំណេះដឹងទូទៅនិងនវានុវត្តន៍ នៅថ្នាក់បរិញ្ញាបត្រ ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់និងថ្នាក់បណ្ឌិត ដោយសហការជាមួយវិស័យឯកជន។<br>• ដាក់បញ្ចូលកម្មវិធីសិក្សាជាក់លាក់ដល់គ្រូដែលបង្រៀនស្ទែមដោយប្រើប្រាស់វិធីសាស្ត្រ និងបច្ចេកទេសបង្រៀនប្រកបដោយគំនិតនវានុវត្តន៍ សម្រាប់គ្រូបង្រៀន កម្មវិធីសិក្សាចំណេះដឹងទូទៅ ឧត្តមសិក្សា និងជីវិតលើប្រធានបទ បច្ចេកវិទ្យាជឿនលឿននិងឈានមុខផ្នែកកម្មន្តសាល ។ | ម៉ូឌែលគំរូ និងគម្រោងទាក់ទិននឹង វ.ប.ន.ដើម្បីឱ្យយុវជនយកគំរូតាម។<br>• លើកកម្ពស់កម្មវិធី "និស្សិតឆ្នើមស្ទែម" ប្រចាំឆ្នាំ។<br>• កសាងបណ្ដាញកិច្ចសហការអន្តរជាតិជាមួយវិទ្យាស្ថានស្រាវជ្រាវនិងគ្រឹះស្ថានឧត្តមសិក្សាដែលឈានមុខ។<br>• ផ្ដួចផ្ដើម និងគាំទ្រដល់កិច្ចសហការដ៏រឹងមាំបន្ថែមទៀតជាមួយវិស័យឯកជន។<br>• ដាក់ឱ្យមានកម្មវិធីចុះកម្មសិក្សានិងហ្វឹកហ្វឺនជាប្រព័ន្ធដល់សិស្ស-និស្សិតផ្នែកស្ទែមនៅតាមសហគ្រាស។<br>• ជំរុញការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល និងឧបករណ៍បច្ចេកទេសទាន់សម័យសម្រាប់ការបង្រៀន និងរៀនពីរបៀបប្រើប្រាស់បច្ចេកវិទ្យារ៉ូបូត សិនស័រ រូបថត និងបច្ចេកវិទ្យាផ្សេងៗ។ | វិទ្យាល័យ និងគ្រឹះស្ថានជីវិតសម្រាប់គ្រូ និងនិស្សិត។<br>• ផ្ដល់ឱកាសសម្រាប់រៀបចំទិវានវានុវត្តន៍ និងវេទិកានវានុវត្តន៍<br>• ផ្ដល់កញ្ចប់ថវិកាគួរឱ្យទាក់ទាញដល់សាស្ត្រាចារ្យ មកពីគ្រឹះស្ថានឧត្តមសិក្សាអន្តរជាតិឈានមុខ<br>• បង្កើតការលើកទឹកចិត្តសម្រាប់និស្សិតទៅសិក្សានៅបរទេសហើយត្រលប់មកប្រទេសវិញដើម្បីចាប់ផ្ដើមអាជីពការងាររបស់ពួកគេ ។<br>• កៀរគរថវិកា (ឧទាហរណ៍ ពីមូលនិធិអភិវឌ្ឍន៍ជំនាញ) ដើម្បីគាំទ្របំពាក់ឧបករណ៍ និងលើកកម្ពស់ "គ្រឹះស្ថានជីវិតឆ្នើម" ចំនួន៥។ |
| | ២០២៣ - ២០៣០ | • បន្តអនុវត្តវិធានការផ្សេងទៀត។ | • បង្កើនសារមន្ទីរវិទ្យាសាស្ត្រនិងបណ្ណាល័យ វ.ប.ន. នៅទូទាំងប្រទេស។ | • សម្របសម្រួល និងជួយគាំទ្រនិស្សិតកម្ពុជាឱ្យទៅសិក្សានៅបរទេស។<br>• បន្តអនុវត្តវិធានការផ្សេងទៀត។ |

## ៣.៣ ការពង្រឹងសមត្ថភាពស្រាវជ្រាវនិងគុណភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានស្រាវជ្រាវសាធារណៈ និងសាកលវិទ្យាល័យ

### *៣.៣.១ គោលដៅគោលនយោបាយ*

គោលបំណងសំខាន់នៃសសរស្តម្ភទី ៣ នេះគឺលើកកម្ពស់ការបង្កើតចំណេះដឹងថ្មីតាមរយៈការពង្រឹងសមត្ថភាពប្រព័ន្ធឧត្តមសិក្សា និងការស្រាវជ្រាវក្នុងការអនុវត្តសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលឆ្លើយតបទៅនឹងផលប្រយោជន៍សង្គម និងតម្រូវការវិស័យឯកជន។ នវានុវត្តន៍ទាមទារឱ្យមានមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រដ៏រឹងមាំនៅក្នុងរយៈពេលយូរអង្វែង។ ពិតណាស់ ការកសាងមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រដ៏រឹងមាំមួយទាមទារឱ្យមានលក្ខខណ្ឌដូចជា របៀបវារៈស្រាវជ្រាវជាតិរួមគ្នា ការប្តេជ្ញាចិត្តយូរអង្វែងពីសំណាក់វិស័យសាធារណៈ និងឯកជនក្នុងការបង្កើនការចំណាយលើការស្រាវជ្រាវនិងអភិវឌ្ឍន៍លើការស្រាវជ្រាវអនុវត្តន៍ (Applied Research) ឬការស្រាវជ្រាវបឋម (Basic Research) ការសហការកាន់តែរឹងមាំរវាងស្ថាប័នជាតិ និងអន្តរជាតិ ដើម្បីបង្កើនគុណភាពស្រាវជ្រាវ ព្រមទាំងការភ្ជាប់ទំនាក់ទំនងជាមួយវិស័យធុរកិច្ច។

ខាងក្រោមនេះគឺជាគោលដៅដែលបានដាក់ចេញដើម្បីពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាពស្រាវជ្រាវ នៅតាមគ្រឹះស្ថានស្រាវជ្រាវសាធារណៈ និងសាកលវិទ្យាល័យ និងដើម្បីវាស់វែងវឌ្ឍនភាព៖

- អនុម័តរបៀបវារៈស្រាវជ្រាវជាតិរយៈពេល ៥ ឆ្នាំដោយកំណត់ទិសដៅនៅក្នុងដែនស្រាវជ្រាវ។
- បង្កើតមូលនិធិស្រាវជ្រាវជាតិឱ្យបានត្រឹមឆ្នាំ២០២៣។
- បង្កើនការចំណាយទៅលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ពី ០,១២% នៃ ផ.ស.ស. (២០១៥)[6] ដល់ ១% ត្រឹមឆ្នាំ២០៣០ ក្នុងនោះ ០,៥% នៃ ផ.ស.ស. បានមកពីវិស័យសាធារណៈ។
- បង្កើនចំនួនអ្នកស្រាវជ្រាវក្នុងវិស័យសាធារណៈពីចំនួន ៣០ នាក់ក្នុងមួយលាននាក់ (២០១៥)[7] រហូតដល់ចំនួន ៧០០ នាក់ក្នុងមួយលាននាក់ ត្រឹមឆ្នាំ២០៣០។
- បង្កើនចំនួននៃការបោះពុម្ពផ្សាយផ្នែកវិទ្យាសាស្ត្រដែលអ្នកនិពន្ធជាអ្នកវិទ្យាសាស្ត្រខ្មែរនៅតាមបណ្តាទិនានុប្បវត្តិអន្តរជាតិ ដែលមានចំនួន ២០៦ អត្ថបទ ក្នុងឆ្នាំ២០១៤ និងជាង ៥០០ អត្ថបទ ក្នុងឆ្នាំ ២០១៨ នេះបើយោងតាម UNESCO Science Report ឱ្យបាន ១ ៥០០ អត្ថបទត្រឹមឆ្នាំ២០៣០។
- បង្កើត កំណត់ និងគាំទ្រសាកលវិទ្យាល័យដែលផ្តោតលើការស្រាវជ្រាវ ឬមជ្ឈមណ្ឌលស្រាវជ្រាវឆ្នើមចំនួន ៧ ដែលផ្តោតការងារលើការស្រាវជ្រាវ និងបច្ចេកវិទ្យា សំដៅផ្តល់ការអប់រំស្រាវជ្រាវតាមស្តង់ដារអន្តរជាតិ «ថ្នាក់បណ្ឌិត» និងផ្តល់នូវការស្រាវជ្រាវដែលមានគុណភាពខ្ពស់ជាមួយដៃគូស្រាវជ្រាវអន្តរជាតិនៅត្រឹមឆ្នាំ២០២៥។

### *៣.៣.២ ការពិពណ៌នាអំពីសកម្មភាព និងលិខិតូបករណ៍*

---

6 UNESCO, 2015: https://data.worldbank.org/indicator/SP.POP.SCIE.RD.P6

7 UNESCO, 2015: https://data.worldbank.org/indicator/SP.POP.SCIE.RD.P6

សកម្មភាព និងលិខិតូបករណ៍ដូចមានរៀបរាប់ខាងក្រោមបានកំណត់ទិសដៅចំនួន ៣ រួមមាន ការកំណត់របៀបវារៈ «ការកំណត់ទិសដៅ» ការផ្តល់មូលនិធិដល់ការស្រាវជ្រាវ និងជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលទាក់ទាញ ក៏ដូចជាការផ្តល់ការលើកទឹកចិត្តសម្រាប់ការងារស្រាវជ្រាវ (តារាងទី ៥)។

*តារាងទី ៥៖ ការពង្រឹងសមត្ថភាពស្រាវជ្រាវ និងគុណភាពស្រាវជ្រាវ*

| | |
|---|---|
| ការកំណត់របៀបវារៈស្រាវជ្រាវជាតិ | ១. ប្រគល់តួនាទីជូន ក.ជ.វ.ប.ន. ក្នុងការដឹកនាំដំណើរការរៀបចំរបៀបវារៈស្រាវជ្រាវជាតិ<br>២. កំណត់របៀបវារៈស្រាវជ្រាវជាតិដោយផ្សារភ្ជាប់ជាមួយវិទ្យាស្ថានស្រាវជ្រាវជាតិ សាកលវិទ្យាល័យ និងវិស័យឯកជន<br>៣. រៀបចំផែនទីបង្ហាញផ្លូវតាមវិស័យ<br>៤. រៀបចំផែនទីបង្ហាញផ្លូវសម្រាប់សាកលវិទ្យាល័យនិងមជ្ឈមណ្ឌលស្រាវជ្រាវថ្មើម<br>៥. បង្កើតកម្មវិធីថ្នាក់ជាតិសម្រាប់ទទួលស្គាល់គុណភាពស្ថាប័នស្រាវជ្រាវ |
| ការផ្តល់មូលនិធិស្រាវជ្រាវនិងអភិវឌ្ឍន៍ដែលទាក់ទាញសម្រាប់ការស្រាវជ្រាវអនុវត្តន៍និងការស្រាវជ្រាវបឋម | ៦. ដាក់បញ្ចូល "ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍" ទៅក្នុងបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា និងកំណត់ទំហំថវិកាអប្បបរមាសម្រាប់គាំទ្រសកម្មភាពនេះ។<br>៧. បង្កើតមូលនិធិស្រាវជ្រាវជាតិ ដើម្បីផ្តល់ជាថវិកាសម្រាប់ទិញឧបករណ៍ប្រើប្រាស់ គម្រោងស្រាវជ្រាវ ការស្រាវជ្រាវបែបសហការ និងការចូលរួមក្នុងបណ្តាញស្រាវជ្រាវអន្តរជាតិ។ |
| ជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការស្រាវជ្រាវ និងផ្តល់ការលើកទឹកចិត្តឱ្យមានសកម្មភាពស្រាវជ្រាវ | ៨. បញ្ចូលវគ្គសិក្សា (Module) ស្តីពីការគ្រប់គ្រងការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវទៅក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។<br>៩. បង្កើតកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យបរទេសឈានមុខដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការស្រាវជ្រាវ។<br>១០. ពង្រឹងយន្តការត្រួតពិនិត្យសមិទ្ធកម្មសម្រាប់អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ។<br>១១. រៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់បុគ្គលិកស្រាវជ្រាវ និងអាហារូបករណ៍ថ្នាក់បណ្ឌិត។ |

## ការកំណត់របៀបវារៈស្រាវជ្រាវជាតិ

ការកំណត់ទិសដៅយុទ្ធសាស្ត្រសម្រាប់កិច្ចការស្រាវជ្រាវ គឺជាភារកិច្ចរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធជាច្រើនដែលគ្រប់គ្រងបណ្តាវិទ្យាស្ថានស្រាវជ្រាវសាធារណៈ។ ក.ជ.វ.ប.ន មានតួនាទីជាស្ថាប័នដឹកនាំដំណើរការកំណត់របៀបវារៈស្រាវជ្រាវជាតិសម្រាប់វិស័យសាធារណៈ និងត្រួតពិនិត្យតាមដានការអនុវត្តការងាររបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ។ ការកំណត់របៀបវារៈស្រាវជ្រាវត្រូវមានការសហការគ្នាជាមួយបណ្តាវិទ្យាស្ថានស្រាវជ្រាវជាតិ អង្គភាពទទួលបន្ទុកការងារស្រាវជ្រាវនៅតាមសាកលវិទ្យាល័យ និងសមាគមវិស័យឯកជន។ លើសពីនេះទៀត វេទិកាសន្ទនាត្រូវតែត្រូវបានផ្តួចផ្តើម ដើម្បីឱ្យមានការប្រើប្រាស់លទ្ធផលស្រាវជ្រាវលើការតាក់តែងគោលនយោបាយ។

ផែនទីបង្ហាញផ្លូវស្រាវជ្រាវតាមវិស័យ ជាអាទិ៍៖ វិស័យកសិកម្ម សុខាភិបាល បច្ចេកវិទ្យាឌីជីថលការអប់រំ កម្មសិទ្ធិបញ្ញា និងវិស័យផ្សេងទៀតដែលបម្រើដល់ប្រព័ន្ធនវានុវត្តន៍ជាតិ គួរតែត្រូវបានបន្តកសាងបន្ថែមលើរបៀបវារៈស្រាវជ្រាវជាតិ ដើម្បីផ្តល់ជាទិសដៅលម្អិតបន្ថែម ដោយមានការសហការជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធ ជាពិសេសវិស័យឯកជន សំដៅឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង។

ផែនទីបង្ហាញផ្លូវស្រាវជ្រាវសម្រាប់សាកលវិទ្យាល័យ និងមជ្ឈមណ្ឌលឆ្នើម ត្រូវតែត្រូវបានកសាងឡើង ដោយផ្តល់អាទិភាពលើការស្រាវជ្រាវលើជំនាញជាក់លាក់ក្នុងវិស័យអាទិភាពរបស់ខ្លួន ដែលកំណត់ពីតម្រូវការកសាងហេដ្ឋារចនាសម្ព័ន្ធ និងបំពាក់ឧបករណ៍ក្នុងបន្ទប់ពិសោធន៍។ បណ្តាស្ថាប័នស្រាវជ្រាវអន្តរជាតិជំនាញត្រូវតែយកមកជាដៃគូ។

ដំណើរការនៃការកំណត់របៀបវារៈស្រាវជ្រាវនេះ នឹងត្រូវតែផ្សំជាមួយការបង្កើតកម្មវិធីវាយតម្លៃទទួលស្គាល់គុណភាពថ្នាក់ជាតិលើស្ថាប័នស្រាវជ្រាវ។

## ការផ្តល់ហិរញ្ញប្បទានសម្រាប់ការស្រាវជ្រាវអនុវត្តន៍ និងការស្រាវជ្រាវបឋម និងអន្តរជាតូបនីយកម្ម

ការគាំទ្ររបស់រាជរដ្ឋាភិបាលលើផ្នែក វ.ប.ន. ផ្តោតលើការជួយទ្រទ្រង់នវានុវត្តន៍នៅតាមក្រុមហ៊ុនសហគ្រាស ដោយរួមមាន ការបង្កើតមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព[8] និងគំនិតផ្តួចផ្តើមផ្សេងទៀត។ ប្រទេសកម្ពុជាគួរតែបង្កើនការវិនិយោគលើសកម្មភាពស្រាវជ្រាវនិងអភិវឌ្ឍន៍ ដែលជាតម្រូវការជាតិជាក់ស្តែង ជាពិសេសក្នុងវិស័យសាធារណៈ ដោយមានការសហការជាមួយវិស័យឯកជន។

សកម្មភាពជាដំបូង ត្រូវដាក់បញ្ចូល «ការស្រាវជ្រាវនិងអភិវឌ្ឍន៍» ទៅក្នុងបេសកកម្មរបស់គ្រឹះស្ថានឧត្តមសិក្សា និងកំណត់ទំហំថវិកាអប្បបរមាដែលផ្តល់ដោយរាជរដ្ឋាភិបាលជូនសាកលវិទ្យាល័យសម្រាប់ចំណាយលើសកម្មភាពស្រាវជ្រាវ។ យន្តការនេះនឹងត្រូវយកទៅអនុវត្តសាកល្បងនៅតាមសាកលវិទ្យាល័យមួយចំនួនតូចដែលផ្តោតលើការស្រាវជ្រាវ ពោលជាសាកលវិទ្យាល័យដែលបានឆ្លងកាត់ការវាយតម្លៃទទួលស្គាល់គុណភាពស្រាវជ្រាវ មុនពេលដាក់ឱ្យដំណើរការនៅថ្នាក់ជាតិ។ ការស្រាវជ្រាវអនុវត្តន៍គឺជាអាទិភាពទីមួយ។

សកម្មភាពបន្ទាប់គឺការបង្កើតមូលនិធិស្រាវជ្រាវជាតិ ដោយផ្អែកលើគំរូរបស់ប្រទេសអភិវឌ្ឍន៍ជឿនលឿនមួយចំនួន ដើម្បីផ្តល់កញ្ចប់ថវិកាដែលទាក់ទាញ ឧទាហរណ៍ដូចជា ការប្រកាសឱ្យដាក់សំណើស្រាវជ្រាវ និងការជ្រើសរើសលើសំណើស្រាវជ្រាវណាដែលឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យគុណភាព ដល់អ្នកស្រាវជ្រាវនីមួយៗ ដូចជា បណ្ឌិត ក្រោយបណ្ឌិតនិងអ្នកស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវ សំដៅគាំទ្រគុណភាពស្រាវជ្រាវ ការធ្វើអន្តរជាតូបនីយកម្មលើការស្រាវជ្រាវ និងការស្រាវជ្រាវបែបសហការនៅក្នុងវិស័យស្រាវជ្រាវអាទិភាព។

[8] បេសកកម្មរបស់មូលនិធិគឺលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ច នវានុវត្តន៍ និងការបង្កើតការងារ។ មូលនិធិផ្តល់ការគាំទ្រដល់ ១) ការលើកកម្ពស់សមត្ថភាព (គាំទ្រសហគ្រាសធុនតូច និងមធ្យម និងធុរកិច្ចថ្មីពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ការប្រឹក្សាយោបល់ លទ្ធភាពចូលទៅក្នុងទីផ្សារ ការអភិវឌ្ឍផលិតផល និងបញ្ហាផ្លូវច្បាប់) ២) ការកសាងបណ្តាញទំនាក់ទំនងក្នុងចំណោមសហគ្រាសធុនតូច និងមធ្យម ៣) ការលើកកម្ពស់វប្បធម៌សហគ្រិនភាព ៤) ការផ្តល់មូលនិធិទ្រទ្រង់ធុរកិច្ចថ្មី (seed funding) ដូចជា ក្នុងទម្រង់ជាមូលនិធិផ្គូរផ្គង (matching grant) ឬសហវិនិយោគសម្រាប់ធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យម។ ប្រភព (https://www.edf-cambodia.com/)

មូលនិធិស្រាវជ្រាវជាតិត្រូវផ្តល់ថវិកាសម្រាប់ការងារដូចខាងក្រោម៖

- ឧបករណ៍ស្រាវជ្រាវនិងបច្ចេកវិទ្យានៅតាមគ្រឹះស្ថានស្រាវជ្រាវសាធារណៈ និងសាកលវិទ្យាល័យ ជាឧទាហរណ៍ ម៉ាស៊ីនធ្វើតេស្ត។
- គម្រោងស្រាវជ្រាវអនុវត្តន៍និងស្រាវជ្រាវបឋម ដែលដឹកនាំដោយក្រុម និងអ្នកស្រាវជ្រាវ ដោយត្រូវឆ្លើយតបទៅនឹងតម្រូវការសង្គម និង/ឬ វិស័យឯកជនស្របតាមរបៀបវារៈស្រាវជ្រាវជាតិ។
- សកម្មភាពស្រាវជ្រាវបែបសហការដែលធ្វើឡើងជាមួយស្ថាប័នស្រាវជ្រាវនៅបរទេសនិងអង្គការមិនមែនរដ្ឋាភិបាល ក៏ដូចជាក្រុមហ៊ុនឯកជន និងអ្នកតាក់តែងគោលនយោបាយនៅក្នុងប្រទេសកម្ពុជា។ ការចូលរួមរបស់អ្នកតាក់តែងគោលនយោបាយ និងស្ថាប័នសាធារណៈមានសារៈសំខាន់ណាស់ក្នុងការជំរុញឱ្យមានការផ្ទេរចំណេះដឹងពីមន្ទីរពិសោធន៍ ទៅលើដំណើរការរៀបចំតាក់តែងគោលនយោបាយ និងការផ្តល់ការរៀបចំគោលនយោបាយដោយពឹងផ្អែកលើទន្និករណ៍ ជាពិសេសការស្រាវជ្រាវក្នុងដែនស្រាវជ្រាវផ្នែកសុខាភិបាល និងកសិកម្ម (Translational Research)។
- ទាក់ទាញអ្នកស្រាវជ្រាវជាន់ខ្ពស់ពីបរទេស ដើម្បីពង្រឹងសមត្ថភាពក្រុមអ្នកស្រាវជ្រាវ និងអ្នកស្រាវជ្រាវជាន់ខ្ពស់នៅក្នុងប្រទេស។
- ផ្តល់មូលនិធិចំពោះការចូលរួមរបស់អ្នកស្រាវជ្រាវគ្រប់លំដាប់ក្នុងបណ្តាញស្រាវជ្រាវអន្តរជាតិគឺជាគន្លឹះក្នុងការទទួលយកចំណេះដឹងនិងបណ្តាញស្រាវជ្រាវសកល ព្រមទាំងទទួលបានអត្ថប្រយោជន៍ពីបទពិសោធន៍ក្នុងការស្រាវជ្រាវរបស់អ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនទៀត។

មូលនិធិស្រាវជ្រាវជាតិត្រូវគ្រប់គ្រងដោយអង្គភាពមួយចំណុះឱ្យក្រសួង ឧ.វ.ប.ន និង ត្រូវចង្អុលទិសដៅដោយ ក.ជ.វ.ប.ន. ផ្អែកលើអាទិភាពក្នុងការផ្តល់មូលនិធិ ស្របតាមរបៀបវារៈស្រាវជ្រាវជាតិ។ ក្នុងការអនុវត្តត្រូវរៀបចំឱ្យមាន៖

- ការផ្តល់វេទិកាសម្រាប់អ្នកស្រាវជ្រាវក្នុងការតាមដាន និងមានឱកាសទទួលបានមូលនិធិ។
- គោលការណ៍ណែនាំ និងនីតិវិធីជាក់លាក់ស្តីពីការប្រើប្រាស់ហិរញ្ញប្បទានស្រាវជ្រាវ ត្រូវរៀបចំនិងផ្សព្វផ្សាយនៅលើវេទិកានោះ

## ជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការស្រាវជ្រាវ និងផ្តល់ការលើកទឹកចិត្តឱ្យមានសកម្មភាពស្រាវជ្រាវ

ដើម្បីជំរុញឱ្យមានប្រព័ន្ធអេកូឡូស៊ី ដែលបង្កបរិយាកាសដល់ការកសាងសមត្ថភាពអ្នកស្រាវជ្រាវ និងភាពទាក់ទាញនៃអាជីពជាអ្នកស្រាវជ្រាវ គេត្រូវអនុវត្តសកម្មភាពមួយចំនួនដូចខាងក្រោម៖

- បញ្ចូលវគ្គសិក្សាស្តីពីការគ្រប់គ្រងការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវទៅក្នុងកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។
- បង្កើតកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យឈានមុខនៅបរទេស ដើម្បីពង្រឹងសមត្ថភាពគ្រប់គ្រងការស្រាវជ្រាវរបស់សាកលវិទ្យាល័យ នៅកម្រិតស្ថាប័ន។

- ដាក់ចេញ និងពង្រឹងយន្តការត្រួតពិនិត្យសមិទ្ធកម្មសម្រាប់អ្នកស្រាវជ្រាវនៅតាមគ្រឹះស្ថានស្រាវជ្រាវសាធារណៈ ព្រមទាំងអ្នកស្រាវជ្រាវ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយនៅតាមសាកលវិទ្យាល័យ រាប់បញ្ចូលទាំងលក្ខណៈវិនិច្ឆ័យទាក់ទងនឹងសកម្មភាពស្រាវជ្រាវ ជាឧទាហរណ៍ដូចជាចំនួនអត្ថបទស្រាវជ្រាវបោះពុម្ពផ្សាយក្នុងទិនានុប្បវត្តិដែលមានការពិនិត្យពីអ្នកជំនាញ និង/ឬ ទិនានុប្បវត្តិអន្តរជាតិ។
- អនុម័តប្រព័ន្ធលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវ សាស្ត្រាចារ្យ សាស្ត្រាចារ្យរង និងសាស្ត្រាចារ្យជំនួយ ក្នុងនោះរួមមាន ការផ្តល់មូលនិធិសិក្សាថ្នាក់បណ្ឌិតនិងកម្មវិធីផ្តល់រង្វាន់ដែលទាក់ទាញ ដោយសំដៅបង្កភាពទាក់ទាញក្នុងអាជីពជាអ្នកស្រាវជ្រាវ ធៀបនឹងវិស័យឯកជន។

### *៣.៣.៣ គោលនយោបាយចម្រុះ*

តារាងទី ៦ ផ្តល់ព័ត៌មានសង្ខេបអំពីបណ្តុំវិធានការដែលត្រូវអនុម័ត។

*តារាងទី ៦៖ គោលនយោបាយចម្រុះ៖ ការស្រាវជ្រាវ*

| សសរស្តម្ភ | ពេលវេលា | លិខិតូបករណ៍គតិយុត្ត | លិខិតូបករណ៍សង្គម និងវប្បធម៌ | លិខិតូបករណ៍ហិរញ្ញវត្ថុ |
|---|---|---|---|---|
| ពង្រឹងសមត្ថភាពស្រាវជ្រាវនិងគុណភាពស្រាវជ្រាវនៅតាមគ្រឹះស្ថានស្រាវជ្រាវសាធារណៈ និងសាកលវិទ្យាល័យ | ២០២១–២០២២ | • ប្រគល់តួនាទីជូន ក.ជ.វ.ប.ន. ក្នុងការកំណត់របៀបវារៈស្រាវជ្រាវជាតិ និងត្រួតពិនិត្យតាមដានការអនុវត្ត<br>• រៀបចំបង្កើតរបៀបវារៈស្រាវជ្រាវជាតិ<br>• បញ្ចូលការស្រាវជ្រាវទៅក្នុងបេសកម្មរបស់សាកលវិទ្យាល័យ «គម្រោងសាកល្បង»<br>• រៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់អ្នកស្រាវជ្រាវដោយផ្អែកលើសមិទ្ធកម្មនៃការស្រាវជ្រាវ | • បង្កើតកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យឈានមុខនៅបរទេស | • ដាក់បញ្ចូលការស្រាវជ្រាវនៅក្នុងផែនការមូលនិធិមូលដ្ឋានយ៉ាងប្រត្យក្សសម្រាប់សាកលវិទ្យាល័យ<br>• បង្កើតមូលនិធិស្រាវជ្រាវជាតិសម្រាប់សាកលវិទ្យាល័យ/មជ្ឈមណ្ឌលឆ្នើម<br>• បង្កើតកម្មវិធី (Fellowship) ដើម្បីទាក់ទាញអ្នកស្រាវជ្រាវអន្តរជាតិមកកាន់ប្រទេសកម្ពុជា |
| | ២០២៣–២០៣០ | • បង្កើតផែនទីបង្ហាញផ្លូវតាមវិស័យសម្រាប់វិស័យអាទិភាព ដូចជាវិស័យ | • បង្កើតឱ្យមានវេទិកាពិភាក្សាជាមួយអ្នករៀបចំគោលនយោបាយ | • ដាក់ចេញនូវប្រព័ន្ធលើកទឹកចិត្តដែលមានភាពទាក់ទាញ |

| | | | | |
|---|---|---|---|---|
| | | បច្ចេកវិទ្យាទំនាក់ទំនង និងព័ត៌មាន កសិកម្ម សុខាភិបាល<br>• កំណត់ផែនទីបង្ហាញផ្លូវដល់សាកលវិទ្យាល័យ/មជ្ឈមណ្ឌលឆ្នើម<br>• បង្កើតកម្មវិធីវាយតម្លៃទទួលស្គាល់គុណភាពថ្នាក់ជាតិលើស្ថាប័នស្រាវជ្រាវ | (Translational Research)<br>• បង្កើតវគ្គបណ្តុះបណ្តាលស្រាវជ្រាវសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិតវិទ្យាសាស្ត្រ | ដូចជា អាហារូបករណ៍ថ្នាក់បណ្ឌិត និងកម្មវិធីផ្តល់រង្វាន់នានា ដល់អ្នកស្រាវជ្រាវ<br>• បន្តកម្មវិធីដែលបានចាប់ផ្តើមរួចហើយ |

## ៣.៤ ការបង្កើនកិច្ចសហការនិងបណ្តាញក្នុងចំណោមតួអង្គពាក់ព័ន្ធនៅក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ៖ ដាក់ចេញនូវវិធីសាស្ត្រ Quadruple Helix

### *៣.៤.១ គោលដៅគោលនយោបាយ*

នវានុវត្តន៍កើតចេញមកពីការផ្លាស់ប្តូរគំនិតនិងបុគ្គល តាមបណ្តាអង្គភាព វិស័យសេដ្ឋកិច្ច និងដែនបច្ចេកវិទ្យា។ អង្គភាពអន្តរការី និងអង្គភាពឈ្មួញកណ្តាលចំណេះដឹងគឺជាតួអង្គដ៏សំខាន់ក្នុងការដើរតួជាអ្នកសម្របសម្រួលឱ្យមានការផ្លាស់ប្តូរគំនិតយោបល់គ្នា តាមរយៈការផ្សារភ្ជាប់គ្នាក្នុងចំណោមតួអង្គពាក់ព័ន្ធផ្នែកនវានុវត្តន៍ ជាអាទិ៍ សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវសាធារណៈ ធុរកិច្ចថ្មី សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក សាជីវកម្មបរទេសធំៗ អ្នកតាក់តែងគោលនយោបាយ និងវិនិយោគិនឯកជនជាដើម។ គោលបំណងសំខាន់នៃសសរស្តម្ភនេះគឺការបង្កើត និងដាក់ចេញនូវប្រព័ន្ធអេកូឡូស៊ីមួយដែលអាចបង្កឱ្យមានកិច្ចសហការតាមបណ្តាតួអង្គ សំដៅបង្កើតគំនិតថ្មីៗនិងនវានុវត្តន៍ ក៏ដូចជាការលើកកម្ពស់ការស្រូបយកនវានុវត្តន៍និងបច្ចេកវិទ្យាថ្មីៗដោយវិស័យឯកជន។ ការអនុវត្តត្រូវតែមានវិសាលភាពទូទាំងប្រទេស ដោយមិនអនុវត្តត្រឹមតែរាជធានីទេ ដើម្បីបញ្ចៀសមិនឱ្យមាន «ការខណ្ឌចែកនវានុវត្តន៍ (Innovation Divide)»។

ខាងក្រោមនេះគឺជាគោលដៅដែលត្រូវអនុវត្ត ដើម្បីកំណត់ទិសសម្រាប់ការវិនិយោគក្នុងវិស័យ វ.ប.ន. និងការអនុវត្តគោលនយោបាយ ព្រមទាំងដើម្បីវាស់វែងវឌ្ឍនភាព៖

- ត្រឹមឆ្នាំ២០២៣ ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាស ត្រូវមានដំណើរការនៅក្នុងសាកលវិទ្យាល័យចំនួន ៥ នៅទូទាំងប្រទេស និងត្រឹមឆ្នាំ២០៣០ ចំនួន ៥០% នៃសាកលវិទ្យាល័យទាំងអស់ត្រូវបង្កើតការិយាល័យនេះ ។
- ត្រឹមឆ្នាំ២០៣០ គ្រប់កម្មវិធីថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រទាំងអស់ត្រូវបញ្ចូលកម្មវិធីចុះកម្មសិក្សានៅតាមរោងចក្រសហគ្រាស យ៉ាងហោចណាស់រយៈពេលពីរខែ។ ត្រឹមឆ្នាំ២០២២ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រចំនួន ៥០ នាក់នឹងត្រូវបញ្ចប់ការសិក្សា ដោយបានចុះកម្មសិក្សា។
- ត្រឹមឆ្នាំ២០២២ រាជរដ្ឋាភិបាលអនុម័តគោលនយោបាយបណ្តុំនិងសួនបច្ចេកវិទ្យានិងនវានុវត្តន៍ និងត្រឹមឆ្នាំ២០២៣ រាជរដ្ឋាភិបាលគាំទ្រគម្រោងសាកល្បងបណ្តុំនិងសួនបច្ចេកវិទ្យានិងនវានុវត្តន៍ជាតិចំនួន ៣ ដោយផ្សារភ្ជាប់សហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក ជាមួយសាជីវកម្មធំៗ និងមជ្ឈមណ្ឌលជីវិត សាកលវិទ្យាល័យ អ្នកស្រាវជ្រាវ និងវិនិយោគិន។ បណ្តុំនិងសួនបច្ចេកវិទ្យានិងនវានុវត្តន៍ជាតិនឹងដំណើរការពេញលេញត្រឹមឆ្នាំ២០២៥។

### *៣.៤.២. ពិព៌ណនាអំពីសកម្មភាព និងលិខិតូបករណ៍*

សកម្មភាព និងលិខិតូបករណ៍ដូចមានរៀបរាប់ខាងក្រោមបានកំណត់ទិសដៅចំនួន ៣ (តារាងទី ៧)។

*តារាងទី ៧៖ បង្កើនកិច្ចសហការ និងបណ្តាញទំនាក់ទំនងរវាងអ្នកពាក់ព័ន្ធក្នុងវិស័យ វ.ប.ន.*

| | |
|---|---|
| ការបើកចំហរបស់សាកលវិទ្យាល័យនិងស្ថាប័នស្រាវជ្រាវសម្រាប់ទទួលវិស័យឯកជន | ១. បង្កើត "ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាស" ជាមួយនឹងបេសកកម្មចំនួន ៣៖<br>• ការអប់រំ ៖ រៀបចំកម្មវិធីសិក្សាដែលឆ្លើយតបទៅនឹងតម្រូវការរបស់វិស័យឯកជន។<br>• ការស្រាវជ្រាវ ៖ ជំរុញកិច្ចសហការលើការស្រាវជ្រាវវិទ្យាសាស្ត្រជាមួយនឹងវិស័យឯកជន។<br>• នវានុវត្តន៍ ៖ ការផ្ទេរចំណេះដឹងនិងការប្រើប្រាស់មន្ទីរពិសោធន៍រួម។ |
| ការដាក់ឱ្យដំណើរការបរិក្ខារឧបទេសភ្ញាស់និងពន្លឿនធុរកិច្ចនៅតាមបណ្តាខេត្តក្រុង ដើម្បីគាំទ្រដល់ការបណ្តុះធុរកិច្ចថ្មី និងការពង្រីកសហគ្រាសធុនតូចនិងមធ្យម | ២. ដាក់ឱ្យដំណើរការបរិក្ខារឧបទេសភ្ញាស់និងពន្លឿនធុរកិច្ចនៅតាមបណ្តាខេត្តក្រុង (មិនត្រឹមតែនៅរាជធានី) ដែលជួយគាំទ្រដល់ការបណ្តុះធុរកិច្ចថ្មី។<br>៣. គាំទ្របរិក្ខារឧបទេសភ្ញាស់និងមជ្ឈមណ្ឌលពន្លឿនធុរកិច្ចនៅតាមបណ្តាសាកលវិទ្យាល័យសម្រាប់ និស្សិត និងសាស្ត្រាចារ្យ ឱ្យមានសហគ្រិនភាព។ |
| ការបង្កើតគម្រោងសាកល្បងបណ្តុំនិងសួនបច្ចេកវិទ្យានិងនវានុវត្តន៍ ដើម្បីជំរុញការផ្ទេរចំណេះដឹង ក្នុងចំណោមក្រុមហ៊ុនធំៗ សហគ្រាសធុនតូចនិងមធ្យម និងគ្រឹះស្ថានឧត្តមសិក្សា និងស្ថាប័នស្រាវជ្រាវ | ៤. សិក្សាពីសមិទ្ធលទ្ធភាពក្នុងការបង្កើតកម្មវិធីបណ្តុំនិងសួនវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា។<br>៥. សួនបច្ចេកវិទ្យានិងនវានុវត្តន៍ ចំនួន ៣ កន្លែង នៅឆ្នាំ ២០២៣ ត្រូវបានដាក់ឱ្យដំណើរការសាកល្បង។ |

## បង្កើនការបើកចំហសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ ដល់វិស័យឯកជននិងសកម្មភាពសហគ្រិនភាព ដើម្បីប្រែក្លាយខ្លួនជាសាកលវិទ្យាល័យសហគ្រិនភាព

ការផ្សារភ្ជាប់គ្រឹះស្ថានឧត្តមសិក្សានិងវិទ្យាស្ថានស្រាវជ្រាវជាមួយវិស័យឯកជន នៅក្នុងដែនស្រាវជ្រាវ និងនវានុវត្តន៍ និងការអប់រំ គឺមានលក្ខណៈទន់ខ្សោយនៅឡើយ។ មានចំណុចជាច្រើនដែលត្រូវជំរុញ សាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ ឱ្យធ្វើការផ្លាស់ប្តូរ ចែករំលែក និងផ្ទេរចំណេះដឹង ក៏ដូចជាមានកិច្ចសហការរួមគ្នា ជាមួយនឹងវិស័យឯកជន។

ក្នុងផែនការរយៈពេលខ្លី រាជរដ្ឋាភិបាលត្រូវគាំទ្រដល់ការបង្កើតការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យនិងសហគ្រាសនៅក្នុងសាកលវិទ្យាល័យគោលដៅមួយចំនួន ជាពិសេសសាកលវិទ្យាល័យដែលផ្តោតលើការស្រាវជ្រាវ និងស្ថាប័នស្រាវជ្រាវសាធារណៈ ដើម្បីបង្កើតទំនាក់ទំនងជិតស្និទ្ធជាមួយ សហព័ន្ធធុរកិច្ចសភាពាណិជ្ជកម្ម និងសហគ្រាសធុនតូចនិងមធ្យម និងសាជីវកម្មធំៗ។ ការបង្កើត «**ការិយាល័យភ្ជាប់ទំនាក់ទំនង សាកលវិទ្យាល័យនិងសហគ្រាស**» មានគោលបំណងចម្បងចំនួនបី៖

- ការអប់រំ៖ ការិយាល័យនឹងជួយសម្រួលដល់ការរៀបចំកម្មវិធីសិក្សារួមគ្នា ដែលមានការចូលរួមរបស់គ្រូដែលមានបទពិសោធន៍ក្នុងវិស័យឯកជន ក្នុងការផ្តល់វគ្គបណ្តុះបណ្តាលជំនាញផ្នែកប្រតិបត្តិការ។

ការិយាល័យនឹងទទួលខុសត្រូវក្នុងការរៀបចំកម្មវិធីចុះកម្មសិក្សារបស់និស្សិតនៅតាមសហគ្រាស និងស្ថាប័នផ្តល់សេវាកម្ម យ៉ាងហោចណាស់ពីរខែសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ។

- ការស្រាវជ្រាវ៖ ការិយាល័យនឹងផ្សារភ្ជាប់និងបង្កើតការជឿទុកចិត្តគ្នារវាងសាកលវិទ្យាល័យ និងវិស័យឯកជន។ ការិយាល័យនេះនឹងរៀបចំព្រឹត្តិការណ៍ផ្គូរផ្គង (Matchmaking Events) ព្រឹត្តិការណ៍បច្ចេកវិទ្យា ការបើកឱ្យចូលទស្សនាមន្ទីរពិសោធន៍សាធារណៈ ដោយមានការចូលរួមពីវិស័យឯកជន និងព្រឹត្តិការណ៍ដទៃទៀតដែលមានសារៈសំខាន់ជួយគាំទ្រដល់ទំនាក់ទំនងរវាងសាកលវិទ្យាល័យ/ស្ថាប័នស្រាវជ្រាវ និងវិស័យឯកជន។ លើសពីនេះទៅទៀត ការិយាល័យអាចប្រមូលគំនិតដែលអាចជាប្រយោជន៍ដល់វិស័យឯកជន ពីមជ្ឈមណ្ឌលស្រាវជ្រាវ ក្នុងគោលដៅផ្តួចផ្តើមគម្រោងបែបសហការដោយមានការចូលរួមពីស្ថាប័នសិក្សាស្រាវជ្រាវនិងវិស័យឯកជន។
- នវានុវត្តន៍៖ ការិយាល័យនឹងសម្រួលការផ្ទេរចំណេះដឹងទៅក្រុមហ៊ុន។ ដើម្បីសម្រេចគោលបំណងនោះ ការិយាល័យនឹងផ្តល់ការគាំទ្រដល់សាកលវិទ្យាល័យនិងក្រុមហ៊ុនឯកជនដែលមានបំណងសហការ ដើម្បីការពារកម្មសិទ្ធិបញ្ញា និងអនុញ្ញាតឱ្យអាជីវកម្មអាចទទួលយកលទ្ធផលនៃការស្រាវជ្រាវ និងប្រើប្រាស់ឧបករណ៍បច្ចេកទេស ជាអាទិ៍៖ មន្ទីរពិសោធន៍និងគំរូដើម (Prototype) ដែលមាននៅតាមសាកលវិទ្យាល័យនិងវិទ្យាស្ថានស្រាវជ្រាវ។

រាជរដ្ឋាភិបាលក៏នឹងលើកទឹកចិត្ត ក្នុងការបង្កើតមន្ទីរពិសោធន៍រួមគ្នា (Joint Laboratory) ក្នុងចំណោម **សាកលវិទ្យាល័យ វិទ្យាស្ថានស្រាវជ្រាវសាធារណៈ និងវិស័យឯកជន** ជាពិសេសជាមួយសាជីវកម្មធំៗ។

ក្នុងផែនការរយៈពេលវែង រាជរដ្ឋាភិបាលនឹងជំរុញ និងគាំទ្រគំនិតនៃការបង្កើតសាកលវិទ្យាល័យសហគ្រិនភាព (Entrepreneurial University[9]) តាមរយៈទិដ្ឋភាពពីរយ៉ាងគឺ៖ ១) សាកលវិទ្យាល័យអាចទទួលយកដំណោះស្រាយបែបសហគ្រិន ដើម្បីឆ្លើយតបនឹងសម្ពាធ និងបញ្ហាប្រឈមដូចដែលបានរៀបរាប់ខាងលើ។ សាកលវិទ្យាល័យក៏អាចផ្លាស់ប្តូរខ្លួនដើម្បីសម្របតាមបរិបទជាក់ស្តែង និងដើម្បីបណ្តុះគំនិតសហគ្រិនភាពតាមរយៈរចនាសម្ព័ន្ធអភិបាលកិច្ច គោលនយោបាយគ្រប់គ្រង និងការអនុវត្តជាក់ស្តែង ជាឧទាហរណ៍ ការអនុញ្ញាតឱ្យមានតំណាងពីវិស័យឯកជននៅក្នុងក្រុមប្រឹក្សាភិបាលសាកលវិទ្យាល័យ។ ២) សាកលវិទ្យាល័យអាចបង្កើតប្រព័ន្ធអេកូឡូស៊ីដែលបង្កប់នូវការបណ្តុះផ្នត់គំនិតនិងឥរិយាបថសហគ្រិនភាព និងត្រូវលើកទឹកចិត្ត គាំទ្រ ជំរុញ និងផ្តល់ជារង្វាន់។

## ដាក់ឱ្យដំណើរការបរិក្ខារឧបទេសភ្ញាស់និងពន្លឿនធុរកិច្ច នៅតាមបណ្តាខេត្ត ដើម្បីគាំទ្រដល់ការបណ្តុះធុរកិច្ចថ្មី និងពង្រីកសហគ្រាសធុនតូចនិងមធ្យម ដោយមិនផ្តោតតែនៅរាជធានី

បច្ចុប្បន្ន គេសង្កេតឃើញថា នៅកម្ពុជាមានការកើនឡើងវត្តមានបរិក្ខារឧបទេសនិងកម្មវិធីភ្ញាស់ និងពន្លឿនធុរកិច្ច មួយចំនួន ក្នុងនោះរួមមាន ការប្រកួតប្រជែងបង្ហាញពីគំនិតអាជីវកម្ម(Pitching Competitions)

---

[9] https://heinnovate.eu/sites/default/files/heinnovate_concept_note.pdf

ដោយមានអមជាមួយការបណ្តុះធុរកិច្ចថ្មីដែលប្រើរយៈពេលខ្លី និងការផ្តល់ជាការិយាល័យសម្រាប់បំពេញការងារជាដើម។ ទោះបីជាយ៉ាងណា កម្មវិធីទាំងនេះមានតិចតួច ហើយភាគច្រើនប្រមូលផ្តុំតែនៅក្នុងរាជធានី និងមិនផ្តោតជាពិសេសទៅលើការបណ្តុះធុរកិច្ចបែបនវានុវត្តន៍ ទាំងផ្អែកនិងមិនផ្អែកលើបច្ចេកវិទ្យា ព្រមទាំងមិនបានភ្ជាប់ការបណ្តុះធុរកិច្ចថ្មី ទៅក្នុងមជ្ឈដ្ឋាននវានុវត្តន៍ធំៗ ជាអាទិ៍៖ សាកលវិទ្យាល័យ សាជីវកម្មធំៗ សហគ្រាសធុនតូចនិងមធ្យម។ ទន្ទឹមគ្នានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគាំទ្រដល់ការបង្កើត **«មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីតេជោ»** ខណៈដែល ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ គាំទ្រដល់ការបង្កើត **«មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មីឌីជីថល»**។

រាជរដ្ឋាភិបាលត្រូវធានាឱ្យបាននូវការដាក់ឱ្យដំណើរការបរិក្ខារឧបទេសភ្ញាស់និងពន្លឿនធុរកិច្ចនៅ ៣ ខេត្តអាទិភាព ដែលជាគម្រោងសាកល្បង មុននឹងពង្រីកនៅកម្រិតថ្នាក់ជាតិ។

- បរិក្ខារឧបទេសទាំងនេះនឹងត្រូវបង្កើតនៅតាមសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវនានា ដើម្បីសម្របសម្រួល ១) ឱ្យវិស័យឯកជនអាចប្រើប្រាស់មន្ទីរពិសោធន៍ មន្ទីរពិសោធន៍បច្ចេកវិទ្យាហ្វេបឡែប (Fabrication Laboratory) ឧបករណ៍ធ្វើគំរូដើម និងតេស្ត និង ២) ការបង្កើតបណ្តុះធុរកិច្ចថ្មី ធុរកិច្ចបុត្រសម្ព័ន្ធថ្មី (Spin-Off) ដោយនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវ។

បរិក្ខារឧបទេសទាំងនេះនឹងត្រូវបានបង្កើតឡើងក្នុងភាពជាដៃគូ និងដោយមានការគាំទ្រពីសមាគមធុរកិច្ចក្នុងស្រុក សហព័ន្ធធុរកិច្ច ដើម្បីឆ្លើយតបទៅនឹងតម្រូវការទីផ្សារ និងតម្រូវការរបស់អតិថិជនប្រកបដោយប្រសិទ្ធភាព។

- បរិក្ខារឧបទេសភ្ញាស់ធុរកិច្ចនឹងស្វែងរកការគាំទ្រ ក៏ដូចជាសហការជាមួយសាជីវកម្មធំៗ នៅក្នុងខេត្ត ដើម្បីជំរុញវិធីសាស្ត្រនវានុវត្តន៍រវាងធុរកិច្ចថ្មី និងក្រុមហ៊ុនធំៗ និងដើម្បីជំរុញសហគ្រិនឱ្យទទួលយកនវានុវត្តន៍ និងស្រូបយកបច្ចេកវិទ្យា។

រាជរដ្ឋាភិបាលត្រូវជួយសម្រួលនិងគាំទ្រដល់វគ្គ «បណ្តុះបណ្តាលគ្រូឧទ្ទេស (Mentors)» ដែលនឹងត្រូវស្នើឡើងទៅកាន់គណៈគ្រប់គ្រងបរិក្ខារឧបទេសនៅក្នុងខេត្តចំនួន ៣ ដែលបានជ្រើសរើស។ ការតាក់តែងវគ្គបណ្តុះបណ្តាលនេះនឹងមានការចូលរួមពីគណៈគ្រប់គ្រងបរិក្ខារឧបទេសភ្ញាស់ដែលមានស្រាប់ ឧទាហរណ៍ មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី ក៏ដូចជាការទទួលយកស្តង់ដារល្អៗពីកម្មវិធីភ្ញាស់និងពន្លឿនធុរកិច្ចអន្តរជាតិ។

## ដាក់ឱ្យដំណើរការសាកល្បងបណ្តុំ និងសួនបច្ចេកវិទ្យានិងនវានុវត្តន៍ ដើម្បីជំរុញកិច្ចសហការ និងការផ្ទេរបច្ចេកវិទ្យា ឬចំណេះដឹង ក្នុងចំណោមក្រុមហ៊ុនធំៗ សហគ្រាសធុនតូចនិងមធ្យម គ្រឹះស្ថានឧត្តមសិក្សា និងស្រាវជ្រាវនៅតាមបណ្តាខេត្ត

ពិតណាស់ ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសនៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៥មក បានទាក់ទាញវិនិយោគពីបរទេសមកកម្ពុជាជាច្រើន បើមិនដូច្នេះទេ នឹងមិនមានវត្តមាននៃការទាក់ទាញវិនិយោគបរទេសទេ ហើយតំបន់សេដ្ឋកិច្ចពិសេសបានបង្កើតការងារយ៉ាងច្រើន។ ប៉ុន្តែ មានភស្តុតាងបញ្ជាក់ថា តំបន់សេដ្ឋកិច្ច

ពិសេសគឺបម្រើឱ្យប្រយោជន៍សេដ្ឋកិច្ចអន្តរជាតិ ជាជាងសេដ្ឋកិច្ចក្នុងស្រុក[10]។ ការផ្ទេរចំណេះដឹង និងបច្ចេកវិទ្យាពីសាជីវកម្មធំៗនិងបណ្តាញក្រុមហ៊ុនម៉ៅការបន្ត (Subcontractor) ជាមួយតួអង្គពាក់ព័ន្ធក្នុងស្រុក និងនៅក្នុងច្រវ៉ាក់តម្លៃ គឺនៅមានកម្រិតទាបនៅឡើយ។

សកម្មភាពដំបូងដែលត្រូវធ្វើនោះគឺការសិក្សាសមិទ្ធលទ្ធភាពនៃការបង្កើតសួនបច្ចេកវិទ្យា និងនវានុវត្តន៍នៅត្រឹមឆ្នាំ២០២២ ដោយអាចភ្ជាប់ខ្លួនជាមួយ ឬបង្កើតនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីជំរុញកិច្ចសហការលើខ្សែច្រវ៉ាក់តម្លៃជាក់លាក់មួយក្នុងចំណោមតួអង្គផ្សេងៗក្នុងខ្សែច្រវ៉ាក់តម្លៃនោះ (Backward/Forward)។ សួនបច្ចេកវិទ្យា និងនវានុវត្តន៍ ត្រូវប្រមូលផ្តុំនូវក្រុមហ៊ុនក្នុងនិងក្រៅតំបន់សេដ្ឋកិច្ចពិសេស រួមទាំងសាកលវិទ្យាល័យក្នុងស្រុក ស្ថាប័នស្រាវជ្រាវ អ្នកតាក់តែងគោលនយោបាយ និងវិនិយោគិន ដែលស្រដៀងទៅនឹងវិធីសាស្ត្របណ្តុំ ដែលផ្តល់ភាពងាយស្រួលដល់ទំនាក់ទំនងក្នុងបណ្តាញដល់អ្នកគ្រប់គ្រង ដើម្បីជួយសម្រួលដល់កិច្ចសហការគ្នារវាងភគិតៈ«អ្នកជួល»ទាំងអស់។ លើសពីនេះទៀត មន្ទីរពិសោធន៍និងបរិក្ខារឧបទេសធ្វើតេស្ត កន្លែងធ្វើការរួមគ្នា ព្រមទាំងកន្លែងធ្វើសន្និបាត ក៏នឹងត្រូវផ្តល់ជូននិងរៀបចំ ទៅតាមតម្រូវការរបស់សួនបច្ចេកវិទ្យានិងនវានុវត្តន៍។

គោលបំណងនៃការបង្កើតនេះ គឺដើម្បីជំរុញការផ្ទេរចំណេះដឹងពីក្រុមហ៊ុនអន្តរជាតិទៅដល់ក្រុមហ៊ុនក្នុងស្រុក ពង្រឹងកិច្ចសហការតាមខ្សែច្រវ៉ាក់តម្លៃ និងកំណត់គំនិតផ្តួចផ្តើមរួមគ្នា ដូចជា ការបង្កើតបរិក្ខារឧបទេសភ្ជាស់ធុរកិច្ចនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ដើម្បីគាំទ្រសហគ្រិនក្នុងស្រុកឱ្យបង្កើតធុរកិច្ចលើបច្ចេកវិទ្យានិងអាជ្ញាប័ណ្ណ ដែលនឹងត្រូវប្រើប្រាស់ដោយសាជីវកម្មធំៗ។

ជំហានបន្ទាប់ ដោយផ្អែកលើលទ្ធផលនៃការសិក្សាសមិទ្ធលទ្ធភាព រាជរដ្ឋាភិបាលអាចដាក់ឱ្យដំណើរការសាកល្បងកម្មវិធីដើម្បីគាំទ្រសួនបច្ចេកវិទ្យា និងនវានុវត្តន៍ចំនួន ៣ ដោយផ្តល់នូវការបណ្តុះបណ្តាលចាំបាច់ និងថវិកាដើម្បីគាំទ្រដល់ក្រុមអ្នកគ្រប់គ្រងបណ្តុំ រួមទាំងតាមរយៈដៃគូអន្តរជាតិ។

## *៣.៤.៣ គោលនយោបាយចម្រុះ*

តារាងទី ៨ ផ្តល់ព័ត៌មានសង្ខេបអំពីសំណុំវិធានការដែលត្រូវអនុម័ត។

*តារាងទី ៨៖ គោលនយោបាយចម្រុះ៖ កិច្ចសហការ និងបណ្តាញ*

| សសរស្តម្ភ | ពេលវេលា | លិខិតូបករណ៍គតិយុត្ត | លិខិតូបករណ៍សង្គម និងវប្បធម៌ | លិខិតូបករណ៍ហិរញ្ញវត្ថុ |
|---|---|---|---|---|
| បង្កើននូវកិច្ចសហការ និងបណ្តាញទំនាក់ទំនងរវាងតួអង្គ | ២០២១-២០២២ | • ការសិក្សាពីសមិទ្ធលទ្ធភាពលើគោលនយោបាយ និង/ឬ កម្មវិធីសម្រាប់ បណ្តុំបែបនវានុវត្តន៍ និង | • គម្រោងសាកល្បងបង្កើត "ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាស" នៅក្នុងសាកលវិទ្យាល័យចំនួន ៥។ | • ដាក់ឱ្យដំណើរការបរិក្ខារឧបទេសភ្ជាស់ និងកម្មវិធីផ្សេងៗនៅតាម |

[10] Peter Warr, Jayant Menon (2015). Cambodia's special economic zones, Asian Development Bank, ADB Economics, Working Paper Series, October. Available at www.adb.org/sites/default/files/publication/175236/ewp-459.pdf.

| | | | | |
|---|---|---|---|---|
| ពាក់ព័ន្ធនៅក្នុងប្រព័ន្ធនវានុវត្តន៍ជាតិ | | សួនបច្ចេកវិទ្យា និងនវានុវត្តន៍ ដោយផ្សារភ្ជាប់ទៅនឹងតំបន់សេដ្ឋកិច្ចពិសេស។ | • គាំទ្រដល់កម្មវិធី "បណ្តុះបណ្តាលគ្រូឧទ្ទេស" ដើម្បីបង្កើនបរិមាណនិងគុណភាពគ្រូឧទ្ទេសនៃសហគ្រិនភាពនៅក្នុងបរិក្ខារឧបទេសភ្ញាស់និងពន្លឿនធុរកិច្ចដែលមានស្រាប់។ | ខេត្តដោយមានភ្ជាប់ទំនាក់ទំនង ជាមួយសាកលវិទ្យាល័យក្នុងស្រុក ឬសភាពាណិជ្ជកម្ម។ |
| | ២០២៣-២០៣០ | • ផ្អែកលើលទ្ធផលនៃការសិក្សាសមិទ្ធលទ្ធភាពសួនបច្ចេកវិទ្យា និងនវានុវត្តន៍ចំនួន ៣ ត្រូវដាក់ឱ្យដំណើរការសាកល្បងចាប់ពីឆ្នាំ ២០២៣ និងដំណើរការពេញលេញនៅឆ្នាំ ២០២៥ | • បង្កើត "ការិយាល័យភ្ជាប់ទំនាក់ទំនងសាកលវិទ្យាល័យ និងសហគ្រាស" ឱ្យបានយ៉ាងតិច ៥០% នៃសាកលវិទ្យាល័យសរុប។<br>• ជំរុញទស្សនទានសាកលវិទ្យាល័យសហគ្រិនភាពក្នុងប្រព័ន្ធអប់រំឧត្តមសិក្សា។<br>• ដាក់ចេញកម្មវិធីចុះកម្មសិក្សានៅក្នុងរោងចក្រសហគ្រាសយ៉ាងហោចណាស់ពីរខែសម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ។<br>• រៀបចំ គ្រប់គ្រង និងបង្កឱ្យវិស័យឯកជនធ្វើការស្រាវជ្រាវ និងប្រើប្រាស់ឧបករណ៍បច្ចេកទេស (Technological Platform) នៅតាមសាកលវិទ្យាល័យ និងស្ថាប័នស្រាវជ្រាវ។<br>• លើកកម្ពស់វិធីសាស្ត្រនវានុវត្តន៍បើកចំហ (Open Innovation) រវាងសាជីវកម្មធំៗនៅក្នុងតំបន់សេដ្ឋកិច្ចពិសេស ជាមួយក្រុមហ៊ុនក្នុងស្រុក ទាំងក្នុងនិងក្រៅតំបន់សេដ្ឋកិច្ចពិសេស និងសាកលវិទ្យាល័យនិងគ្រឹះស្ថានជីវតេ។ | • ផ្តល់ថវិកាដើម្បីពង្រីកកិច្ចសហការរវាងសាកលវិទ្យាល័យនិងសហគ្រាស។<br>• ផ្តល់ជំនួយថវិកាដល់អ្នកគ្រប់គ្រងបណ្តុំនិងសួន។ |

## ៣.៥. ការជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការកសាងសមត្ថភាពស្រូបយកនៅក្នុងក្រុមហ៊ុន និងទាក់ទាញការវិនិយោគនៅក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

### *៣.៥.១. គោលដៅគោលនយោបាយ*

នៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ រាជរដ្ឋាភិបាលកម្ពុជាមានចក្ខុវិស័យជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មនៅកម្ពុជា ពីឧស្សាហកម្មអតិពលកម្មឈានទៅឧស្សាហកម្មផ្អែកលើជំនាញត្រឹមឆ្នាំ២០២៥ តាមរយៈការតភ្ជាប់ទៅនឹងខ្សែច្រវ៉ាក់តម្លៃសកល សមាហរណកម្ម ទៅក្នុងបណ្តាញផលិតកម្មតំបន់ និងការអភិវឌ្ឍបណ្តុំផលិតកម្មប្រទាក់ក្រឡា ទន្ទឹមនឹងការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាពឧស្សាហកម្មក្នុងស្រុក ហើយបន្តឈានទៅអភិវឌ្ឍឧស្សាហកម្មទំនើប ដែល ផ្អែកជាសំខាន់លើមូលដ្ឋានបច្ចេកវិទ្យា និងចំណេះដឹង។ ផែនទីបង្ហាញផ្លូវ វ.ប.ន. កម្ពុជា ២០៣០ នឹងជួយធ្វើឱ្យសម្រេចបានចក្ខុវិស័យនេះ ដោយពង្រឹងសមត្ថភាពសហគ្រាសធុនតូច និងមធ្យមធ្វើនវានុវត្តន៍ និងស្រូបយកបច្ចេកវិទ្យា ចំណេះធ្វើ និងជំនាញកម្រិតខ្ពស់តាមរយៈការផ្ទេរបច្ចេកវិទ្យា ជួយសម្រួលដល់ការទទួលបានមូលនិធិ និងលើកទឹកចិត្តដល់ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសក្នុងវិស័យ វ.ប.ន. ព្រមទាំងភ្ជាប់ទំនាក់ទំនង និងកិច្ចសហការជាមួយសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក បន្ថែមពីលើការជួយគាំទ្រក្នុងការផ្តល់កម្លាំងពលកម្មប្រកបដោយជំនាញសម្រាប់នវានុវត្តន៍(សូមមើលផ្នែក ៣.២)។

ខាងក្រោមនេះគឺជាគោលដៅដែលបានដាក់ចេញដើម្បីតម្រង់ទិសការវិនិយោគក្នុងវិស័យ វ.ប.ន. និងការអនុវត្តគោលនយោបាយជាតិ វ.ប.ន. ព្រមទាំងដើម្បីវាស់វែងវឌ្ឍនភាព៖

- ការវិនិយោគជារួមនៅក្នុងការស្រាវជ្រាវនិងអភិវឌ្ឍន៍ ស្មើ ១% នៃ ផ.ស.ស. ត្រឹមឆ្នាំ២០៣០ ក្នុងនោះ ០,៥% នៃ ផ.ស.ស. មានប្រភពចេញពីវិស័យឯកជន ធៀបនឹង ០,១២% នៃ ផ.ស.ស. ក្នុងឆ្នាំ ២០១៥។
- ពិន្ទុរបស់ប្រទេសកម្ពុជានៅក្នុងសន្ទស្សន៍នវានុវត្តន៍សកលត្រូវខ្ពស់ជាងកម្រិតមធ្យមនៃសមាជិករបស់សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ត្រឹមឆ្នាំ២០៣០។
- ត្រឹមឆ្នាំ២០២៣ យន្តការនិងច្បាប់ផ្ទេរបច្ចេកវិទ្យានឹងត្រូវបានបង្កើតនិងដាក់ឱ្យដំណើរការពេញលេញ។
- ត្រឹមឆ្នាំ២០២៣ របបកម្មសិទ្ធិបញ្ញាត្រូវបានពង្រឹងតាមរយៈយន្តការសមស្របនានា ដូចជាយុទ្ធសាស្ត្រគាំពារ។

### *៣.៥.២. ពិពណ៌នាអំពីសកម្មភាព និងលិខិតូបករណ៍*

តួនាទីរបស់ក្រសួង ឧ.វ.ប.ន. គឺជាគន្លឹះសំខាន់បំផុតក្នុងការជានាឱ្យមានការអភិវឌ្ឍទម្រង់ថ្មីៗ ដែលគាំទ្រដល់សមត្ថភាពនវានុវត្តន៍ និងការស្រូបយកបច្ចេកវិទ្យានៅក្នុងក្រុមហ៊ុន ព្រមទាំងស្របតាមគោលនយោបាយជាតិ វ.ប.ន. ឆ្នាំ២០២០-២០៣០។ សកម្មភាពនិងលិខិតូបករណ៍ដែលបានស្នើឡើងនឹងផ្តោតលើទិសដៅចំនួន ៣ (តារាងទី ៩)។

*តារាងទី ៩៖ ការជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការកសាងសមត្ថភាពស្រូបយករបស់ក្រុមហ៊ុន និងទាក់ទាញការវិនិយោគនៅក្នុងវិស័យ វ.ប.ន.*

| | |
|---|---|
| លើកកម្ពស់សមត្ថភាពនវានុវត្តន៍របស់សហគ្រាសធុនតូចនិងមធ្យម | ១. បញ្ចូលទម្រង់គាំទ្រនានាដូចជា សេវាកម្មបច្ចេកវិទ្យា សេវាកម្មគាំទ្រសំដៅការពង្រីកខ្លួន វគ្គសិក្សាស្ដីពីការគ្រប់គ្រងនវានុវត្តន៍ និង កម្មវិធីបង្វឹកផ្សេងៗ។<br>២. បង្កើតកម្មវិធីប្រកួតប្រជែង និងផ្ដល់រង្វាន់លើសហគ្រិនភាព និងនវានុវត្តន៍។<br>៣. បង្កើតច្បាប់ផ្ទេរបច្ចេកវិទ្យាដើម្បីជំរុញការផ្ទេរបច្ចេកវិទ្យាពីសាកលវិទ្យាល័យទៅកាន់វិស័យឯកជន រវាងអន្តរវិស័យ និងពីក្រុមហ៊ុនបរទេសទៅកាន់ក្រុមហ៊ុនក្នុងស្រុក និងសម្រួលដល់ការបញ្ជ្រាបបច្ចេកវិទ្យាទំនើបឈានមុខដើម្បីពង្រឹងសមត្ថភាពនវានុវត្តន៍។<br>៤. បង្កើតស្ថាប័នពង្រឹងការអនុវត្តច្បាប់របបកម្មសិទ្ធិបញ្ញា វិញ្ញាបនបត្រកម្ម និងស្ដង់ដារ។ |
| បង្កើនលទ្ធភាពទទួលនិងប្រើប្រាស់ហិរញ្ញប្បទាននវានុវត្តន៍សម្រាប់សហគ្រាសធុនតូច និងមធ្យម | ៥. រៀបចំបណ្ដាវេទិកាសម្រាប់ការត្រៀមលក្ខណៈក្នុងការវិនិយោគ ជាអាទិ៍៖ ព្រឹត្តិការណ៍កសាងបណ្ដាញ ព្រឹត្តិការណ៍ទាក់ទាញធុរកិច្ចថ្មី (Pitching Event) ដល់វិនិយោគិន និងសហគ្រាសធុនតូច និងមធ្យម។<br>៦. បង្កើតអនុគោលដៅជាក់លាក់ សម្រាប់ធនាគារសហគ្រាសធុនតូច និងមធ្យម និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ដើម្បីឈានទៅអភិវឌ្ឍសមត្ថភាពនវានុវត្តន៍ និងចាប់យកបច្ចេកវិទ្យា។<br>៧. សិក្សាវិភាគគម្លាតទីផ្សារនៃការទទួលបានហិរញ្ញប្បទានរបស់សហគ្រាសធុនតូច និងមធ្យមក្នុងការធ្វើនវានុវត្តន៍។ |
| ទាក់ទាញ និងលើកទឹកចិត្តដល់ការវិនិយោគផ្ទាល់ពីបរទេសឱ្យវិនិយោគក្នុងវិស័យ វ.ប.ន. និងសហការជាមួយសហគ្រាសធុនតូច និងមធ្យមក្នុងស្រុក | ៨. ស្នើបញ្ចូលកញ្ចប់លើកទឹកចិត្តជាក់លាក់ណាមួយទៅក្នុងច្បាប់វិនិយោគថ្មី ដើម្បីទាក់ទាញជាពិសេសវិនិយោគិនអន្តរជាតិក្នុងវិស័យដែលផ្អែកលើបច្ចេកវិទ្យា ការវិនិយោគលើការស្រាវជ្រាវនិងអភិវឌ្ឍន៍ ក៏ដូចជាការផ្ទេរបច្ចេកវិទ្យា និងចំណេះធ្វើទៅកាន់ឱ្យសហគ្រាសធុនតូច និងមធ្យម។ |

## លើកកម្ពស់សមត្ថភាពនវានុវត្តន៍របស់សហគ្រាសធុនតូចនិងមធ្យម

លទ្ធភាពរបស់សហគ្រាសធុនតូច និងមធ្យមមួយដែលអាចធ្វើនវានុវត្តន៍បាន ពោលគឺចេះផ្សាំខ្លួនទៅនឹងការប្រែប្រួលលក្ខខណ្ឌផ្សេងៗ និងតម្រូវការរបស់អតិថិជន មានសារៈសំខាន់ណាស់សម្រាប់ភាពប្រកួតប្រជែងរយៈពេលយូរអង្វែង និងភាពស្ថិតស្ថេររបស់សហគ្រាស។ សកម្មភាពទី ១ គឺ រាជរដ្ឋាភិបាលនឹងរៀបចំ

បង្កើតទម្រង់សេវាកម្មគាំទ្រនានាដែលផ្តោតលើសហគ្រាសធុនតូច និងមធ្យម សំដៅផ្តល់សេវាកម្មបច្ចេកវិទ្យា សេវាកម្មប្រឹក្សាយោបល់សម្រាប់ពង្រីកលើការវិនិយោគ ពន្ធដារនិងច្បាប់ វគ្គសិក្សាលើការគ្រប់គ្រងនវានុវត្តន៍ និងកម្មវិធីបណ្តុះបណ្តាលផ្សេងៗ ព្រមទាំងការប្រកួតប្រជែងលើសហគ្រិនភាពនិងនវានុវត្តន៍។ លើសពីនេះទៀត ច្បាប់ស្តីពីការផ្ទេរបច្ចេកវិទ្យាត្រូវតែត្រូវបានបង្កើតឡើង ក្នុងគោលបំណងលើកកម្ពស់ការផ្ទេរបច្ចេកវិទ្យា ចំណេះធ្វើ ជំនាញកម្រិតខ្ពស់ និងទេពកោសល្យ ពីសាកលវិទ្យាល័យ វិស័យឯកជន និងក្រៅប្រទេស សំដៅផ្តល់អត្ថប្រយោជន៍ដល់វិស័យដទៃទៀត (Beneficial Externality) សម្រាប់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ច ជាពិសេសទៅកាន់សហគ្រាសធុនតូច និងមធ្យមសំដៅពង្រឹងសមត្ថភាពនវានុវត្តន៍របស់ខ្លួន។

សកម្មភាពទី ២ គឺការជំរុញនិងពង្រឹងការអនុវត្តរបបច្បាប់កម្មសិទ្ធិបញ្ញា វិញ្ញាបនបត្រកម្ម និងស្តង់ដារជាពិសេសតាមរយៈ ១) ការគាំទ្រសកម្មភាពអនុវត្តបទប្បញ្ញត្តិដែលមានស្រាប់ សំដៅជានា និងលើកទឹកចិត្តការបង្កើតនវានុវត្តន៍ និងការផ្ទេរបច្ចេកវិទ្យា និង ២) យុទ្ធនាការផ្តល់ព័ត៌មានស្តីពីកម្មសិទ្ធិបញ្ញា និងវិញ្ញាបនបត្រកម្ម ឬស្តង់ដារតាមរយៈសមាគមអាជីវកម្ម។

សកម្មភាពទី ៣ គឺការផ្តល់ការលើកលែងពន្ធនាំចូលពិសេសសម្រាប់ក្រុមហ៊ុនក្នុងស្រុកដែលនាំចូលឧបករណ៍ប្រើប្រាស់ក្នុងមន្ទីរពិសោធន៍ ដើម្បីអនុវត្តសកម្មភាពសិក្សាស្រាវជ្រាវ និងនវានុវត្តន៍។

### បង្កើនឱ្យមាន និងទទួលបានហិរញ្ញប្បទានសម្រាប់នវានុវត្តន៍ដល់សហគ្រាសធុនតូចនិងមធ្យម

សកម្មភាពទី ១ មានគោលបំណង លើកកម្ពស់ការវិនិយោគ និងការត្រៀមលក្ខណៈរបស់វិនិយោគិននៅក្នុងប្រទេស សំដៅកាត់បន្ថយគម្លាតក្នុងការទទួលបានហិរញ្ញប្បទាន៖

- រៀបចំវេទិកា ជាអាទិ៍៖ សន្និសីទ ព្រឹត្តិការណ៍កសាងបណ្តាញទំនាក់ទំនង ក្នុងគោលដៅបង្កើនការត្រៀមលក្ខណៈរបស់វិនិយោគិន ដូចជាធនាគារពាណិជ្ជ មូលនិធិវិនិយោគផ្សងព្រេង (Venture Capital Fund) ជាដើម ដើម្បីវិនិយោគទៅលើសហគ្រាសធុនតូច និងមធ្យមដែលមានលក្ខណៈនវានុវត្តន៍ និងវិនិយោគលើបច្ចេកវិទ្យា។
- រៀបចំព្រឹត្តិការណ៍ពាក់ព័ន្ធនឹងការត្រៀមលក្ខណៈក្នុងការវិនិយោគដើម្បីបណ្តុះបណ្តាលសហគ្រាសធុនតូចនិងមធ្យមលើការគ្រប់គ្រងហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងការរៀបចំកម្មវិធីទាក់ទាញធុរកិច្ចថ្មីដល់វិនិយោគិន សំដៅលើកកម្ពស់ចំណេះដឹងអំពីហិរញ្ញវត្ថុជូនសហគ្រាសធុនតូចនិងមធ្យម និងអ្នកគ្រប់គ្រងសហគ្រាស ជាដើម។
- ផ្សារភ្ជាប់កម្មវិធី និងបរិក្ខារឧបទេសភ្ញាស់និងពន្លឿនធុរកិច្ចថ្មី ទៅនឹងវិនិយោគិន ដើម្បីជំរុញពួកគេឱ្យក្លាយទៅជាគ្រូឧទ្ទេស ឬជាដៃគូយុទ្ធសាស្ត្ររបស់សហគ្រាសធុនតូច និងមធ្យម។

សកម្មភាពទី ២ មានគោលបំណងផ្តល់លិខិតូបករណ៍ក្នុងការផ្តល់មូលនិធិដល់សហគ្រាសធុនតូច និងមធ្យមដើម្បីធ្វើនវានុវត្តន៍ និងវិនិយោគក្នុងការទទួលយកបច្ចេកវិទ្យា។

- ធនាគារសហគ្រាសធុនតូច និងមធ្យម និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាពនឹងត្រូវដាក់ឱ្យដំណើរការក្នុងកម្រិតថ្នាក់ជាតិ ដោយត្រូវជំរុញ និងផ្តោតលើសហគ្រាសធុនតូច និងមធ្យមដែលមានស្រាប់ និងដែលវិនិយោគលើសកម្មភាពនវានុវត្តន៍ និងទទួលយកបច្ចេកវិទ្យា ជាពិសេសនៅក្នុងផ្នែកកែច្នៃកសិផល

កម្មន្តសាល និងសេដ្ឋកិច្ចឌីជីថល។ ក្រសួង ឧ.វ.ប.ន. នឹងសម្របសម្រួលជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលើការងារនេះ។

- ផ្ដែកលើការពិនិត្យសិក្សាលើផលប័ត្រវិនិយោគ (Investment Portfolio) របស់ធនាគារសហគ្រាសធុនតូចនិងមធ្យម និងមូលនិធិអភិវឌ្ឍន៍សហគ្រិនភាព ការសិក្សាវិភាគគម្លាតនៃការទទួលបានហិរញ្ញប្បទានលើការងារនវានុវត្តន៍នឹងត្រូវធ្វើឡើងជាមួយវិស័យឯកជន ដើម្បីតាក់តែងលិខិតូបករណ៍ហិរញ្ញប្បទានថ្មីសម្រាប់បំពេញនូវគម្លាតហិរញ្ញប្បទានក្នុងការងារនវានុវត្តន៍តាមរយៈការផ្ដល់ហិរញ្ញប្បទានឥតសំណង ឬលិខិតូបករណ៍ហិរញ្ញវត្ថុផ្សេងៗដូចជា ប្រាក់ខ្ចី ការធានារ៉ាប់រង ឬមូលធន។
- ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលត្រូវបន្តគាំទ្រវិធានការដែលជួយសម្រួលដល់ការបង្កើតជាផ្លូវការនៃធុរកិច្ចថ្មីនិងសហគ្រាសធុនតូចនិងមធ្យម មានលទ្ធភាពទទួលបានការគាំទ្រផ្នែកហិរញ្ញវត្ថុជាសាធារណៈ។

### ទាក់ទាញ និងលើកទឹកចិត្តវិនិយោគិនផ្ទាល់ពីបរទេសឱ្យសហការជាមួយសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក និងផ្ទេរបច្ចេកវិទ្យានិងចំណេះធ្វើ

ច្បាប់វិនិយោគផ្ដល់កញ្ចប់លើកទឹកចិត្តសម្រាប់ការវិនិយោគផ្ទាល់ពីបរទេសលើ "គម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់" ដែលទទួលស្គាល់ដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ យន្តការលើកទឹកចិត្តសម្រាប់ការវិនិយោគ រួមមាន ការលើកលែងពន្ធលើប្រាក់ចំណូលរហូតដល់ ៩ ឆ្នាំ អាស្រ័យលើលក្ខណៈសម្បត្តិនៃគម្រោងវិនិយោគ ការសម្រួលផ្ដល់រម្លស់ពិសេស (Special Depreciation Facility) ការលើកលែងពន្ធនាំចូលលើគ្រឿងម៉ាស៊ីន ឧបករណ៍ ជាតុចូលសម្រាប់ផលិតកម្ម វត្ថុធាតុដើម និងសម្ភារផ្សេងៗទៀត។ រាជរដ្ឋាភិបាលកំពុងធ្វើវិសោធនកម្មច្បាប់ស្ដីពីវិនិយោគ។ ក្រសួង ឧ.វ.ប.ន. នឹងសម្របសម្រួលជាមួយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីស្នើដាក់បញ្ចូលកញ្ចប់លើកទឹកចិត្តទៅក្នុងច្បាប់នេះសម្រាប់ទាក់ទាញវិនិយោគិនអន្តរជាតិណាដែល ១) វិនិយោគក្នុងវិស័យដែលផ្អែកលើបច្ចេកវិទ្យាជាមូលដ្ឋាន ២) វិនិយោគលើសកម្មភាពនៃការស្រាវជ្រាវនិងអភិវឌ្ឍន៍ ឬសកម្មភាពនៃការផ្ទេរបច្ចេកវិទ្យានិងចំណេះដឹង ៣) ប្ដេជ្ញាចិត្តសហការជាមួយសហគ្រាសធុនតូចនិងមធ្យម និងអ្នកផ្គត់ផ្គង់ក្នុងស្រុកតាមរយៈការផ្ទេរបច្ចេកវិទ្យា និងចំណេះធ្វើ និង/ឬ ៤) សហការជាមួយគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុក និងស្ថាប័នស្រាវជ្រាវសាធារណៈផ្សេងៗ កម្មវិធីបណ្ដុះបណ្ដាល ការស្រាវជ្រាវនិងអភិវឌ្ឍន៍។

### *៣.៥.៣. គោលនយោបាយចម្រុះ*

តារាងទី ១០ សង្ខេបខ្លឹមសារសំខាន់ៗពាក់ព័ន្ធនឹងសំណុំវិធានការសម្រាប់អនុវត្ត។

*តារាងទី ១០៖ គោលនយោបាយចម្រុះ៖ ប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសល្អ*

| សសរស្ដម្ភ | រយៈពេល | លិខិតូបករណ៍គតិយុត្ត | លិខិតូបករណ៍សង្គម និងវប្បធម៌ | លិខិតូបករណ៍ហិរញ្ញវត្ថុ |
|---|---|---|---|---|
| ជំរុញប្រព័ន្ធអេកូឡូស៊ីដែលបង្កបរិយាកាសដល់ការ | ២០២១-២០២២ | • ពង្រឹកសមត្ថកិច្ចរបស់ធនាគារសហគ្រាសធុនតូចនិងមធ្យមដើម្បីគាំទ្រការ | • បង្កើតកម្មវិធីប្រកួតប្រជែងលើនវានុវត្តន៍និងសហគ្រិនភាព។ | • ផ្ដោតលើគម្រោងផ្ដល់មូលនិធិដែលទើបបង្កើតថ្មីនិង |

| | | | | |
|---|---|---|---|---|
| គាំទ្រសមត្ថភាពស្រូបយកនវានុវត្តន៍របស់សហគ្រាសធុនតូច និងមធ្យម និងការទាក់ទាញការវិនិយោគក្នុងវិស័យ វ.ប.ន. | | វិនិយោគលើការស្រាវជ្រាវ និងអភិវឌ្ឍន៍ និងនវានុវត្តន៍របស់សហគ្រាសធុនតូច និងមធ្យម។<br>• បញ្ចូលការលើកទឹកចិត្តនៅក្នុងច្បាប់វិនិយោគដើម្បីទាក់ទាញវិយោគិនផ្ទាល់ពីបរទេសដែលវិនិយោគលើសកម្មភាពដែលផ្តល់តម្លៃបន្ថែម និងការស្រាវជ្រាវ និង/ឬដែលសហការជាមួយបណ្តាក្រុមហ៊ុនក្នុងស្រុក និងជាមួយសាកលវិទ្យាល័យក្នុងស្រុក និងស្ថាប័នស្រាវជ្រាវសាធារណៈ។<br>• បង្កើតច្បាប់ផ្ទេរបច្ចេកវិទ្យាដើម្បីជំរុញការបញ្ជ្រាបបច្ចេកវិទ្យា ជាពិសេសទៅកាន់សហគ្រាសធុនតូច និងមធ្យមសំដៅដល់ការពង្រឹងសមត្ថភាពនវានុវត្តន៍។ | • បង្កើតវគ្គសិក្សា និងកម្មវិធីបង្វឹកដល់សហគ្រិន។<br>• បង្កើតវគ្គសិក្សា និងកម្មវិធីបង្វឹកលើការគ្រប់គ្រងនវានុវត្តន៍។<br>• ផ្តល់បច្ចេកវិទ្យានិងសេវាកម្មសម្រាប់ពង្រីកធុរកិច្ច។<br>• បង្កើនការត្រៀមលក្ខណៈសម្រាប់វិនិយោគិន។<br>• ពង្រឹងការអនុវត្តរបបកម្មសិទ្ធិបញ្ញា។ | ដែលមានស្រាប់ ដូចជា មូលនិធិអភិវឌ្ឍន៍សហគ្រិនភាព និងធនាគារសហគ្រាសធុនតូច និងមធ្យម ដើម្បីឈាន ទៅរកនវានុវត្តន៍។<br>• សិក្សាវិភាគគម្លាតទីផ្សារនៃការទទួលបានហិរញ្ញប្បទានរបស់សហគ្រាសធុនតូច និងមធ្យម ក្នុងការធ្វើនវានុវត្តន៍។ |
| | ២០២៣-២០៣០ | | • បន្តសកម្មភាពទំនាក់ទំនងនិងការយល់ដឹងទាក់ទិនសហគ្រិនភាពនិងនវានុវត្តន៍។ | • តាក់តែងលិខិតូបករណ៍ហិរញ្ញប្បទានថ្មីសម្រាប់បំពេញនូវគម្លាតហិរញ្ញប្បទានក្នុងការងារនវានុវត្តន៍ ជាពិសេសដំណាក់កាលត្រៀម និងចាប់ផ្តើម។ |

# ឧបសម្ព័ន្ធ

## បញ្ជីរាយនាមក្រសួងស្ថាប័នពាក់ព័ន្ធដែលបានពិគ្រោះយោបល់

**ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**
- អគ្គនាយកដ្ឋានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- អគ្គនាយកដ្ឋានឧស្សាហកម្ម
- អគ្គនាយកដ្ឋានសហគ្រាសធុនតូចនិងមធ្យម និងសិប្បកម្ម
- វិទ្យាស្ថានជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍
- វិទ្យាស្ថានស្តង់ដារកម្ពុជា

**សមាជិកគណៈប្រឹក្សាយោបល់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍-របស់ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍**

**អតីតក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យារបស់ក្រសួងផែនការ**

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ

**ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ**

**ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**
- អគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ
- វិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ

**ក្រសួងអប់រំ យុវជន និងកីឡា**
- អគ្គនាយកដ្ឋានឧត្តមសិក្សា
- អគ្គនាយកដ្ឋានគោលនយោបាយ និងផែនការ

**ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍**
- អគ្គនាយកដ្ឋានបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

**ក្រសួងពាណិជ្ជកម្ម**
- អគ្គនាយកដ្ឋានពាណិជ្ជកម្មអន្តរជាតិ
- អគ្គនាយកដ្ឋានជំរុញពាណិជ្ជកម្ម

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
- អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**
- អគ្គនាយកដ្ឋានកសិកម្ម

**ក្រសួងសុខាភិបាល**
- អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល

**ក្រសួងផែនការ**
- អគ្គនាយកដ្ឋានផែនការ
- វិទ្យាស្ថានជាតិស្ថិតិ

**ក្រសួងសាធារណការ និងដឹកជញ្ជូន**
- អគ្គនាយកដ្ឋានភស្តុភារកម្ម
- អគ្គនាយកដ្ឋានផែនការ និងគោលនយោបាយ

**ក្រសួងមហាផ្ទៃ**
- អគ្គស្នងការដ្ឋាននគរបាលជាតិ

**ក្រសួងការពារជាតិ**
- កងយុទ្ធពលខេមរភូមិន្ទ

**ក្រសួងមុខងារសាធារណៈ**

**ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**មជ្ឈមណ្ឌលបណ្តុះធុរកិច្ចថ្មី «តេជោ»**

**ធនាគារសហគ្រាសធុនតូច និងមធ្យមកម្ពុជា**

**សម្ព័ន្ធសមាគមសហគ្រាសធុនតូច និងមធ្យមកម្ពុជា**

**សភាពាណិជ្ជកម្មកម្ពុជា**

**វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា**

**សាកលវិទ្យាល័យភូមិន្ទភ្នំពេញ**

**សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

**វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

**វិទ្យាស្ថានជាតិពហុបច្ចេកវិទ្យាកម្ពុជា**

**វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

**វិទ្យាស្ថានបច្ចេកវិទ្យាគិរីរម្យ**

**វិទ្យាស្ថានចក្ខុវិស័យអាស៊ី**

Impact Hub Company

Small World Venture

ក្រុមហ៊ុន Amru Rice

ក្រុមហ៊ុន GGear Group

ក្រុមហ៊ុន ISI Group

ក្រុមហ៊ុន ម៉ុង ឫទ្ធី គ្រុប

ក្រុមហ៊ុន Royal Group

ក្រុមហ៊ុន Bongloy

ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)

ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)

ធនាគារពិភពលោក (WB)




ISBN 978-9924-9556-2-7